# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រម

០៧-៤-២០០៦ -ព្រះរាជក្រម នស/រកម/០៤០៦/០០៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុល រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ១៩០៨

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៣-៤-២០០៦ -អនុក្រឹត្យលេខ ១៩៧ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ១៩៧៩

០៣-៤-២០០៦ -អនុក្រឹត្យលេខ ១៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៩៨១

០៥-៤-២០០៦ -អនុក្រឹត្យលេខ ១៩៩ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ១៩៨៣

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០០ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ១៩៨៥

## III-ការិយាល័យក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១១-០១-២០០៦ -លិខិតលេខ ១៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីនសេង គ្រីនធីង (ខេមបូឌា)** ១៩៨៦

១១-០១-២០០៦ -លិខិតលេខ ១៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធនាគារ ឯកទេស អានកូ** ១៩៨៨

១១-០១-២០០៦ -លិខិតលេខ ១៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អ៊ិនធើណេសិនណល គ្រេឌីង** ១៩៩០

១២-០១-២០០៦ -លិខិតលេខ ១៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វណ្ណា ស្រីពៅ ខូ អិលធីឌី** ១៩៩២

១២-០១-២០០៦ -លិខិតលេខ ១៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាល់ធី-ប៊ីហ្សនេស & អ៊ីមផត អិចផត** ១៩៩៤

១២-០១-២០០៦ -លិខិតលេខ ១៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី & ហ្សេត អ៊ិនវេសមេន** ១៩៩៦

១២-០១-២០០៦ -លិខិតលេខ ១៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច ហុង ម៉េង ពាណិជ្ជ** ១៩៩៨

១២-០១-២០០៦ -លិខិតលេខ ១៦៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មុខ ការ៉េម** ២០០០

១២-០១-២០០៦ -លិខិតលេខ ១៦៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆ៉ាច យ៉ាំង (ខេមបូឌា)** ២០០២

១២-០១-២០០៦ -លិខិតលេខ ១៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មើហ្វីស តីធីវ៉ាយ អិលធីឌី** ២០០៤

១២-០១-២០០៦ -លិខិតលេខ ១៧២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដារ៉ា ម៉ាញូនីង អង្គរ (ខេមបូឌា)** ២០០៦

១២-០១-២០០៦ -លិខិតលេខ ១៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជ្រេហ្គាន រ៉ូយ៉ាល់ ឆេលីខម** ២០០៨

១២-០១-២០០៦ -លិខិតលេខ ១៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ាយអឺលេស អ៊ិនធើណេត**
**ប្រូវ៉ាយឌើរ** ២០១០

២៥-០១-២០០៦ -លិខិតលេខ ៣២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្ស្រាមម៉ានីត ស្គុំត** ២០១២

១៤-០២-២០០៦ -លិខិតលេខ ៤៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អានីស** ២០១៤

១៧-០២-២០០៦ -លិខិតលេខ ៤៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីនហាន (ខេមបូឌា)** ២០១៦

១៧-០២-២០០៦ -លិខិតលេខ ៤៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ វឌ្ឍនះ ខបភើរេសិន** ២០១៨

២០-០២-២០០៦ -លិខិតលេខ ៥២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វើលវ៉ាយដ៍ ធីស៊ី ត្រាវ៉ែល** ២០២០

២២-០២-២០០៦ -លិខិតលេខ ៥៦៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូនីដា ខូ អិលធីឌី** ២០២២

២២-០២-២០០៦ -លិខិតលេខ ៥៦៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីម គ្រុប** ២០២៤

២២-០២-២០០៦ -លិខិតលេខ ៥៧០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេ អិល ប្រាឌើរ ខបភើរេសិន** ២០២៦

២២-០២-២០០៦ -លិខិតលេខ ៥៧១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លៀង អ៊ុ (ខេមបូឌា) ភាតុង** ២០២៨

២៣-០២-២០០៦ -លិខិតលេខ ៥៧៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូគ្រូ សួវ៉ាយ ភីធីអ៊ី អិលធីឌី** ២០៣០

២៣-០២-២០០៦ -លិខិតលេខ ៥៧៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីនើស ផ្លីស ខូ អិលធីឌី** ២០៣១

២៣-០២-២០០៦ -លិខិតលេខ ៥៧៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខ ផូរផង់ ត្រេឌីង អ៊ិមផត អិចផត** ២០៣៣

# ព្រះរាជក្រម

នស/រកម/០៤០៦/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុល រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

34/

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុល
## រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុលរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណ-រដ្ឋសង្គមនិយមវៀតណាម ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

នស/រកម.០៤០៦.០១៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ហត្ថលេខា**

**ហោ ណាំហុង**

លេខ: ១៦៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# អនុសញ្ញាកុងស៊ុល

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# និង

# សាធារណរដ្ឋសង្គមនិយមវៀតណាម

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលអំណឹះតទៅហៅថា "ភាគីចុះកិច្ចសន្យា"

- ដោយមានបំណងពង្រីកនិងពង្រឹងថែមទៀត នូវចំណងមិត្តភាពនិងទំនាក់ទំនងជាប្រពៃណី រវាងប្រទេសទាំងពីរ

- ដោយប៉ងប្រាថ្នាដោះស្រាយនិងពង្រីកថែមទៀត នូវទំនាក់ទំនងកុងស៊ុល ព្រមទាំងបង្កលក្ខណៈអនុគ្រោះដល់កិច្ចការពារសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់ របស់ពលរដ្ឋនៃភាគីចុះកិច្ចសន្យាម្ខាង ដែលស្នាក់នៅក្នុងទឹកដីរបស់ភាគីចុះកិច្ចសន្យាម្ខាងទៀត ស្របតាមច្បាប់និងទំលាប់អន្តរជាតិ

បានសំរេចចុះអនុសញ្ញាកុងស៊ុលនេះ ហើយនៅក្នុងទិសដៅនេះ បានព្រមព្រៀងគ្នាដូចតទៅ :

## ជំពូក I

## មាត្រា ១

## និយមន័យ

ក្នុងក្របខ័ណ្ឌអនុសញ្ញានេះ ពាក្យពេចន៍ដែលចែងខាងក្រោម មានន័យដូចតទៅ :

១. *"ប៉ុស្តិ៍កុងស៊ុល"* មានន័យថា ស្ថានអគ្គកុងស៊ុល ស្ថានកុងស៊ុល អនុកុងស៊ុល និង ភ្នាក់ងារកុងស៊ុល

២. *"មណ្ឌលកុងស៊ុល"* មានន័យថា តំបន់ដែលកំណត់សំរាប់ប៉ុស្តិ៍កុងស៊ុលណាមួយ ដើម្បីបំពេញមុខងារកុងស៊ុល

៣. *"ប្រធានប៉ុស្តិ៍កុងស៊ុល"* មានន័យថា ជនដែលត្រូវបានចាត់តាំងឱ្យបំពេញមុខងារ កុងស៊ុល ក្នុងឋានៈនេះ

៤. *"មន្ត្រីកុងស៊ុល"* មានន័យថា រាល់ជនទាំងឡាយណា រួមទាំងប្រធានប៉ុស្តិ៍កុងស៊ុល ដែលត្រូវបានចាត់តាំងឱ្យបំពេញមុខងារកុងស៊ុល ក្នុងឋានៈនេះ

៥. *"និយោជិកកុងស៊ុល"* មានន័យថា រាល់ជនទាំងឡាយណា ដែលត្រូវចាត់ឱ្យបំរើ ការងារ ក្នុងសេវាបច្ចេកទេស ឬ រដ្ឋបាល របស់ប៉ុស្តិ៍កុងស៊ុល

៦. *"សមាជិកបំរើការងារ"* មានន័យថា រាល់ជនដែលចាត់ឱ្យបំរើការងារផ្ទះ នៅក្នុង ប៉ុស្តិ៍កុងស៊ុល

៧. *"សមាជិកនៃបុគ្គលិកកុងស៊ុល"* មានន័យថា មន្ត្រីកុងស៊ុល និយោជិកកុងស៊ុល និង សមាជិកបុគ្គលិកបំរើការ

៨. *"សមាជិកនៃបុគ្គលិកកុងស៊ុល"* មានន័យថា មន្ត្រីកុងស៊ុល ក្រៅពីប្រធានប៉ុស្តិ៍ កុងស៊ុល និយោជិកកុងស៊ុល និង សមាជិកបុគ្គលិកបំរើការ

៩. *"សមាជិកនៃបុគ្គលិកឯកជន"* មានន័យថា រាល់ជនដែលចាត់ឱ្យបំរើការងារឯកជន ដាច់មុខ ជូនសមាជិកប៉ុស្តិ៍កុងស៊ុល

១០. *"ទីស្ថានកុងស៊ុល"* មានន័យថា អាគារ ឬ ផ្នែកនានានៃអាគារ និង ផ្ទៃដីជាប់ នឹងអាគារនោះ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ឱ្យតែប្រើប្រាស់ដាច់មុខ ក្នុងផលប្រយោជន៍ របស់ប៉ុស្តិ៍កុងស៊ុល

១១. *"សារស្ថានកុងស៊ុល"* រួមមាន រាល់ក្រដាសស្នាម ឯកសារ លិខិតឆ្លើយឆ្លង សៀវភៅមើល ខ្សែភាពយន្ត ឧបករណ៍បច្ចេកទេសសំរាប់ទទួលនិងតំកល់ពត៌មាន សៀវភៅបញ្ជី របស់ប៉ុស្តិ៍កុងស៊ុល ព្រមទាំងលេខនិងអក្សរសំងាត់ បញ្ជីកែសារនិងរាល់គ្រឿងសង្ហារឹម ប្រើប្រាស់ សំរាប់តំកល់ទុកនិងការពារឯកសារទាំងនោះ

១២. *"លិខិតឆ្លើយឆ្លងជាផ្លូវការ"* មានន័យថា រាល់ការឆ្លើយឆ្លងពាក់ព័ន្ធដល់ប៉ុស្តិ៍ កុងស៊ុល និង ការងាររបស់ប៉ុស្តិ៍កុងស៊ុល

១៣. *"សមាជិកគ្រួសាររបស់មន្ត្រីកុងស៊ុល ឬ និយោជិកកុងស៊ុល"* មានន័យថា ភរិយា ឬ ស្វាមី និង កូនអាយុក្រោម១៨ឆ្នាំ របស់មន្ត្រីនិងនិយោជិកកុងស៊ុល ដែលរួមរស់ក្នុង

បន្ទុកគ្រួសាររបស់មន្ត្រី ឬ នយោជិកនោះ

១៤. *"នាវា"* មានន័យថា នាវាស៊ីវិលណាមួយ ដែលដោតទង់ជាតិរបស់រដ្ឋដាក់កុងស៊ុល ស្របតាមច្បាប់របស់រដ្ឋដាក់កុងស៊ុល ដោយមិនរាប់បញ្ចូល នាវាចំបាំង

១៥. *"អាកាសយាន"* មានន័យថា អាកាសយានស៊ីវិល ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងរដ្ឋដាក់កុងស៊ុល ដែលមានសិទ្ធិប្រើប្រាស់សញ្ញាសំគាល់ការចុះបញ្ជីរបស់រដ្ឋនោះ ប៉ុន្តែមិនរាប់បញ្ចូលយន្តហោះយោធាទេ ។

## ជំពូក II

## បទបញ្ញត្តិទូទៅស្តីពីទំនាក់ទំនងកុងស៊ុល

## មាត្រា ២

## ការបង្កើតប៉ុស្តិ៍កុងស៊ុល

១. ប៉ុស្តិ៍កុងស៊ុលអាចបង្កើតនៅក្នុងដែនដីរដ្ឋម្ចាស់ផ្ទះបាន លុះត្រាតែមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ ។

២. ទីតាំង លំដាប់ថ្នាក់ និង មណ្ឌលកុងស៊ុល របស់ប៉ុស្តិ៍កុងស៊ុល ក៏ដូចជាចំនួនសមាជិកនៃបុគ្គលិកកុងស៊ុល ត្រូវកំណត់ដោយរដ្ឋដាក់កុងស៊ុល និង ត្រូវមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ ។

៣. រាល់ការផ្លាស់ប្តូរដោយថាហេតុណាមួយ នៃទីតាំងលំដាប់ថ្នាក់និងមណ្ឌលកុងស៊ុលរបស់ប៉ុស្តិ៍កុងស៊ុល អាចធ្វើបានដោយរដ្ឋដាក់កុងស៊ុល លុះត្រាតែមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះតែប៉ុណ្ណោះ ។

៤. ត្រូវឱ្យមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះផងដែរ ក្នុងករណីស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល មានបំណងបើកស្ថានអនុកុងស៊ុល ឬ ក៏ទីភ្នាក់ងារកុងស៊ុល នៅកន្លែងមួយផ្សេងទៀតពីកន្លែងដែលស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលតាំងនៅ ។

៥. ត្រូវឱ្យមានការយល់ព្រមជាក់លាក់ជាមុនពីរដ្ឋម្ចាស់ផ្ទះផងដែរ ចំពោះការបើកការិយាល័យណាមួយ ដែលជាផ្នែកមួយនៃប៉ុស្តិ៍កុងស៊ុលដែលមានរួចហើយ នៅកន្លែងមួយផ្សេងទៀតពីទីតាំងរបស់ប៉ុស្តិ៍កុងស៊ុល ។

## មាត្រា ៣
## ការតែងតាំង និង ការទទួលស្គាល់ជាប្រធានប៉ុស្តិ៍កុងស៊ុល

១. មុននឹងតែងតាំងប្រធានប៉ុស្តិ៍កុងស៊ុលដោយរដ្ឋដាក់កុងស៊ុល ត្រូវមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ លើបុគ្គលដែលត្រូវតែងតាំងនោះ តាមរយៈផ្លូវទូត ឬ ផ្លូវណាផ្សេងទៀត ដែលសមស្រប ។

២. រដ្ឋម្ចាស់ផ្ទះ ដែលបដិសេធការយល់ព្រមទៅលើបុគ្គល ដែលត្រូវតែងតាំងជាប្រធានប៉ុស្តិ៍កុងស៊ុល មិនចាំបាច់ផ្តល់ទៅរដ្ឋដាក់កុងស៊ុល ពីមូលហេតុនៃការបដិសេធនេះទេ ។

៣. រដ្ឋដាក់កុងស៊ុលនឹងបញ្ជូនទៅរដ្ឋម្ចាស់ផ្ទះ តាមរយៈផ្លូវទូត ឬ ផ្លូវណាផ្សេងទៀត ដែលសមស្រប នូវឯកសារមួយមានរូបភាពជាលិខិតបំរុងតាំងកុងស៊ុល ឬ ឯកសារមានតំលៃប្រហាក់ប្រហែលគ្នា ស្តីពីការតែងតាំងប្រធានប៉ុស្តិ៍កុងស៊ុល ។ ឯកសារនេះ នឹងកំណត់អំពីឋានៈរបស់ប្រធានប៉ុស្តិ៍កុងស៊ុល និង ជំរាបអំពីនាមនិងគោត្តនាម ថ្នាក់របស់គេ មណ្ឌលប៉ុស្តិ៍កុងស៊ុល និង ទីតាំងនៃប៉ុស្តិ៍កុងស៊ុល ។

៤. ក្រោយពីបានទទួលលិខិតសារបំរុងតាំង ឬ ឯកសារមានតំលៃប្រហាក់ប្រហែលគ្នា ស្តីពីការតែងតាំងប្រធានប៉ុស្តិ៍កុងស៊ុលហើយ រដ្ឋម្ចាស់ផ្ទះនឹងចេញលិខិតអនុញ្ញាតដែលហៅថា លិខិតនិកាសទាន ឬ លិខិតអនុញ្ញាតផ្សេងទៀត ជូនដល់ប្រធានប៉ុស្តិ៍កុងស៊ុល ។

៥. លើកលែងតែករណីដូចបានកំណត់ក្នុងកថាខ័ណ្ឌទី៦នៃមាត្រានេះ និង មាត្រាទី៤នៃអនុសញ្ញានេះ ប្រធានប៉ុស្តិ៍កុងស៊ុលអាចចូលបំពេញមុខងាររបស់ខ្លួនបាន តែនៅក្រោយការផ្តល់លិខិតនិកាសទាន ឬ លិខិតអនុញ្ញាតណាមួយផ្សេងទៀត ។

៦. ក្នុងការរង់ចាំការផ្តល់លិខិតនិកាសទាន ឬ លិខិតអនុញ្ញាតផ្សេងទៀត តាមការស្នើសុំរបស់រដ្ឋដាក់កុងស៊ុល រដ្ឋម្ចាស់ផ្ទះអាចអនុញ្ញាតឱ្យប្រធានប៉ុស្តិ៍កុងស៊ុល បំពេញមុខងាររបស់ខ្លួនជាបណ្តោះអាសន្ន ។ ក្នុងករណីនេះ បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ នឹងត្រូវយកមកអនុវត្ត ។

៧. ក្រោយពីប្រធានប៉ុស្តិ៍កុងស៊ុលទទួលការអនុញ្ញាតឱ្យបំពេញមុខងាររបស់ខ្លួន ទោះក្នុងលក្ខណៈបណ្តោះអាសន្នក្តី រដ្ឋម្ចាស់ផ្ទះត្រូវជូនពត៌មានជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ចនៃមណ្ឌលកុងស៊ុល ។ រដ្ឋម្ចាស់ផ្ទះត្រូវធានាផងដែរថា វិធានការចាំបាច់ទាំងឡាយត្រូវបានចាត់ដើម្បីសំរួលដល់ប្រធានប៉ុស្តិ៍កុងស៊ុល ក្នុងការបំពេញភារកិច្ចរបស់ខ្លួន និង ទទួលអត្ថប្រយោជន៍ពីបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

## មាត្រា ៤

## ការអនុវត្តនីតិវិធីមុខងាររបស់ប្រធានប៉ុស្តិ៍កុងស៊ុលជាបណ្តោះអាសន្ន

១. ប្រសិនបើប្រធានប៉ុស្តិ៍កុងស៊ុលមិនអាចបំពេញមុខងាររបស់ខ្លួនបាន ឬ ប្រសិនបើតំណែងប្រធានប៉ុស្តិ៍កុងស៊ុលនៅទំនេរនោះ ប្រធានស្តីទីអាចដំណើរការងារជាប្រធានប៉ុស្តិ៍កុងស៊ុលជាបណ្តោះអាសន្ន ។

២. នាមនិងគោត្តនាមរបស់ប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី ត្រូវបញ្ជូនទៅក្រសួងការបរទេសរដ្ឋម្ចាស់ផ្ទះ តាមរយៈបេសកកម្មការទូតរបស់រដ្ឋដាក់កុងស៊ុល ឬ តាមរយៈប្រធានប៉ុស្តិ៍កុងស៊ុល ប្រសិនបើគ្មានបេសកកម្មការទូតនៅក្នុងរដ្ឋម្ចាស់ផ្ទះ ឬ តាមរយៈអាជ្ញាធរសមត្ថកិច្ចនៃរដ្ឋដាក់កុងស៊ុល ក្នុងករណីប្រធានប៉ុស្តិ៍កុងស៊ុលមិនអាចធ្វើការងារនេះបាន ។ តាមក្បួនជាទូទៅ ការផ្តល់ព័ត៌មាននេះត្រូវផ្តល់ជូនឱ្យបានមុន ។ ក្នុងលក្ខខណ្ឌដែលមានការយល់ព្រមពីខ្លួន រដ្ឋម្ចាស់ផ្ទះអាចទទួលយកបុគ្គលដែលមិនមែនជាភ្នាក់ងារការទូត ឬ មន្ត្រីកុងស៊ុលរបស់រដ្ឋដាក់កុងស៊ុល ឱ្យធ្វើជាប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី ។

៣. អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋម្ចាស់ផ្ទះ នឹងផ្តល់ការជួយឧបត្ថម្ភនិងកិច្ចការពារជូនប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី ។ ក្នុងរយៈពេលទទួលភារកិច្ចជាបណ្តោះអាសន្ននេះ បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ត្រូវយកមកអនុវត្តទាំងស្រុងចំពោះប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី ដូចគ្នានឹងប្រធានប៉ុស្តិ៍កុងស៊ុលពេញសិទ្ធិដែរ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋម្ចាស់ផ្ទះមិនចាំបាច់ផ្តល់ជូនប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី នូវភាពងាយស្រួល បុព្វសិទ្ធិ ឬ អភ័យឯកសិទ្ធិទាំងឡាយ ដែលការប្រើប្រាស់សិទ្ធិទាំងនោះដោយប្រធានប៉ុស្តិ៍កុងស៊ុល ត្រូវស្ថិតនៅក្រោមលក្ខណៈដែលប្រធានប៉ុស្តិ៍កុងស៊ុលស្តីទីនោះខ្លួនឯងមិនអាចបំពេញបាន ។

៤. ប្រសិនបើ ក្នុងស្ថានភាពដូចមានចែងនៅក្នុងកថាខណ្ឌ១នៃមាត្រានេះ សមាជិកនៃបុគ្គលិកការទូតនៃបេសកកម្មការទូតរបស់រដ្ឋដាក់កុងស៊ុលណាមួយ បានទទួលការតែងតាំងដោយរដ្ឋនោះជាប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី សមាជិកបុគ្គលិកការទូតនោះនៅបន្តទទួលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិការទូតដដែល ក្នុងករណីដែលរដ្ឋម្ចាស់ផ្ទះមិនជំទាស់ ។

## មាត្រា ៥

## ការតែងតាំងសមាជិកនៃបុគ្គលិកកុងស៊ុល

១. លើកលែងតែបទបញ្ញត្តិនៃមាត្រា២, ៦ និង ៧ នៃអនុសញ្ញានេះ រដ្ឋដាក់កុងស៊ុលអាចតែងតាំងសមាជិកនៃបុគ្គលិកកុងស៊ុលបានដោយសេរី ។

២. រដ្ឋដាក់កុងស៊ុល ត្រូវជូនពត៌មានអំពីនាមនិងគោត្តនាម ប្រភេទនិងថ្នាក់ របស់មន្ត្រីកុងស៊ុលនិមួយៗ ក្រៅពីប្រធានប៉ុស្តិ៍កុងស៊ុល ទៅរដ្ឋម្ចាស់ផ្ទះ ក្នុងថេរៈវេលាមួយគ្រប់គ្រាន់សំរាប់រដ្ឋម្ចាស់ផ្ទះអនុវត្តសិទ្ធិរបស់ខ្លួន ស្របតាមកថាខ័ណ្ឌ៣នៃមាត្រា៧ ប្រសិនបើរដ្ឋម្ចាស់ផ្ទះមានបំណងធ្វើដូច្នោះ ។

៣. អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ នឹងចេញឯកសារបញ្ជាក់អត្តសញ្ញាណ និងតួនាទី ជូនដល់សមាជិកប៉ុស្តិ៍កុងស៊ុល សមាជិកគ្រួសាររបស់គេ និង សមាជិកនៃបុគ្គលិកឯកជនដោយឥតគិតថ្លៃ ក្នុងករណីដែលជនទាំងនោះមិនមែនជាពលរដ្ឋរបស់រដ្ឋម្ចាស់ផ្ទះ ឬ ជាជនដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ ។

## មាត្រា ៦
## សញ្ជាតិរបស់មន្ត្រីកុងស៊ុល

១. ជាគោលការណ៍ មន្ត្រីកុងស៊ុលត្រូវជាជនជាតិរបស់រដ្ឋដាក់កុងស៊ុល ។

២. មន្ត្រីកុងស៊ុលអាចត្រូវតែងតាំងពីចំណោមជនមានសញ្ជាតិរបស់រដ្ឋម្ចាស់ផ្ទះ ឬ ជនដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះបាន លុះត្រាតែមានការយល់ព្រមជាក់លាក់ពីរដ្ឋម្ចាស់ផ្ទះ ហើយរដ្ឋម្ចាស់ផ្ទះអាចដកការយល់ព្រមនេះនៅពេលណាក៏បាន ។

៣. រដ្ឋម្ចាស់ផ្ទះអាចរក្សាសិទ្ធិរបស់ខ្លួន ស្របតាមកថាខ័ណ្ឌ២នៃមាត្រានេះ ចំពោះពលរដ្ឋនៃប្រទេសទី៣ ដែលមិនកាន់សញ្ជាតិរបស់រដ្ឋដាក់កុងស៊ុលផងដែរ ។

## មាត្រា ៧
## បុគ្គលមិនជាទីពេញចិត្ត ឬ មិនអាចទទួលយកបាន

១. រដ្ឋម្ចាស់ផ្ទះអាចជូនពត៌មានគ្រប់ពេល ទៅរដ្ឋដាក់កុងស៊ុលថា មន្ត្រីកុងស៊ុលណាមួយ ជាបុគ្គលមិនជាទីពេញចិត្ត ឬ សមាជិកណាមួយទៀតនៃបុគ្គលិកកុងស៊ុល ជាបុគ្គលមិនអាចទទួលយកបាន ។ ក្នុងសភាពការណ៍បែបនេះ រដ្ឋដាក់កុងស៊ុលអាចហៅបុគ្គលពាក់ព័ន្ធនោះត្រឡប់មកវិញ ឬ បញ្ចប់មុខងាររបស់បុគ្គលនោះ ក្នុងប៉ុស្តិ៍កុងស៊ុលទៅតាមករណីនិមួយៗ ។

២. ប្រសិនបើរដ្ឋដាក់កុងស៊ុលបដិសេធ ឬ ខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចបានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ ក្នុងកាលវេលាមួយសមស្រប រដ្ឋម្ចាស់ផ្ទះអាចដកនិក្ខេបបទ ឬ លិខិតអនុញ្ញាតិផ្សេងៗទៀត ពីបុគ្គលពាក់ព័ន្ធនោះ ឬ ក៏ឈប់ចាត់ទុកបុគ្គលនោះ ជាសមាជិកនៃបុគ្គលិកកុងស៊ុល តាមករណីនិមួយៗ ។

៣. បុគ្គលដែលត្រូវបានតែងតាំងជាសមាជិកនៃប៉ុស្តិ៍កុងស៊ុល អាចត្រូវបានគេប្រកាសថា មិនអាចទទួលយកបាន មុនពេលមកដល់ទឹកដីរដ្ឋម្ចាស់ផ្ទះ ឬ ក៏មុនពេលចូលកាន់មុខងាររបស់ខ្លួនក្នុងប៉ុស្តិ៍កុងស៊ុល ក្នុងករណីដែលបានមកនៅក្នុងរដ្ឋម្ចាស់ផ្ទះហើយ ។ ក្នុងករណីនេះ រដ្ឋដាក់កុងស៊ុល នឹងដកការតែងតាំងនេះចេញវិញ ។

៤. ក្នុងករណីដូចបានចែងក្នុងកថាខណ្ឌ ១ និង ៣ នៃមាត្រានេះ រដ្ឋម្ចាស់ផ្ទះមិនតំរូវឱ្យផ្តល់មូលហេតុជូនរដ្ឋដាក់កុងស៊ុល ពីការសំរេចចិត្តរបស់ខ្លួនឡើយ ។

## មាត្រា ៨

## ការផ្តល់ពត៌មានដល់រដ្ឋម្ចាស់ផ្ទះ អំពីការតែងតាំង ការអញ្ជើញមកដល់ និង ការចាកចេញ

១. ក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ឬ អាជ្ញាធរដែលក្រសួងនេះបានចាត់តាំង ត្រូវបានទទួលពត៌មានអំពី :

ក- ការតែងតាំងសមាជិកប៉ុស្តិ៍កុងស៊ុល ការអញ្ជើញមកដល់របស់អ្នកទាំងនោះ ក្រោយពីបានទទួលការតែងតាំងនៅប៉ុស្តិ៍កុងស៊ុល ការចាកចេញជាស្ថាពរ ឬ ការបញ្ចប់មុខងាររបស់សមាជិកទាំងនោះ និង ការផ្លាស់ប្រែប្រួលផ្សេងៗទៀត ដែលប៉ះពាល់ដល់ស្ថានភាពអ្នកទាំងនោះ ដែលនឹងអាចកើតមានឡើង ក្នុងកំឡុងបំពេញការងាររបស់ខ្លួននៅប៉ុស្តិ៍កុងស៊ុល ។

ខ- ការអញ្ជើញមកដល់ និង ការចាកចេញជាស្ថាពរ នៃជនជាសមាជិកគ្រួសាររបស់សមាជិកប៉ុស្តិ៍កុងស៊ុល និង មូលហេតុដែលនាំឱ្យបុគ្គលណាម្នាក់ក្លាយជា ឬ លែងជាសមាជិកនៃគ្រួសារនេះ ប្រសិនបើមាន ។

គ- ការមកដល់ និង ការចាកចេញជាស្ថាពរ របស់សមាជិកនៃបុគ្គលិកឯកជន និង ការបញ្ចប់ការងាររបស់ជននោះ ប្រសិនបើមាន ។

ឃ- ការទទួលឱ្យធ្វើការ និង ការបញ្ឈប់ការងាររបស់ជនដែលមានលំនៅក្នុងរដ្ឋម្ចាស់ផ្ទះ ក្នុងឋានៈជាសមាជិកប៉ុស្តិ៍កុងស៊ុល ឬ ជាសមាជិកបុគ្គលិកឯកជន ដែលមានសិទ្ធិទទួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ។

២. ប្រសិនបើអាចធ្វើបាន ដំណឹងស្តីពីការមកដល់ និង ការចាកចេញជាស្ថាពរ ត្រូវ

ផ្តល់ជូនមកមុន ។

## មាត្រា ៩
## ការកាន់កាប់ទីស្ថានកុងស៊ុល និង លំនៅស្ថាន

១. រដ្ឋដាក់កុងស៊ុលមានសិទ្ធិធ្វើដោយខ្លួនឯងផ្ទាល់ ឬ ក៏តាមរយៈរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយដែលខ្លួនចាត់តាំង ដើម្បីកាន់កាប់ជាម្ចាស់កម្មសិទ្ធិ ធ្វើកិច្ចសន្យាជួល ឬ តាមរូបភាពកាន់កាប់ផ្សេងៗទៀត ស្របតាមច្បាប់និងបទបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ និង ដោយមានការអនុញ្ញាតពីរដ្ឋម្ចាស់ផ្ទះនោះផង :

ក- ទីស្ថានកុងស៊ុល លំនៅស្ថានសំរាប់ប្រធានប៉ុស្តិ៍កុងស៊ុល និង លំនៅស្ថានសំរាប់មន្ត្រីកុងស៊ុលនិងនយោជិកកុងស៊ុលនិមួយៗ ដែលមិនមែនជាពលរដ្ឋ ឬ អ្នករស់នៅជាអចិន្ត្រៃយ៍នៃរដ្ឋម្ចាស់ផ្ទះ ។

ខ- ដី ទីស្ថាន និង លំនៅស្ថានសង់នៅលើដីនោះ ។

២. ក្នុងលក្ខខ័ណ្ឌយោងតាមកថាខ័ណ្ឌ១ រដ្ឋដាក់កុងស៊ុលក៏អាចជួសជុលកែលំអទីស្ថាន លំនៅស្ថាន ឬ ដីនោះ ។

៣. រដ្ឋម្ចាស់ផ្ទះនឹងផ្តល់ការឧបត្ថម្ភគាំទ្រសមស្របសព្វបែបយ៉ាង ដល់រដ្ឋដាក់កុងស៊ុលក្នុងការប្រើសិទ្ធិដូចមានចែងក្នុងកថាខ័ណ្ឌ១និង២ នៃមាត្រានេះ ។

៤. រដ្ឋដាក់កុងស៊ុលត្រូវគោរពតាមច្បាប់និងបទបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ ស្តីពីគំរោងសាងសង់និងប្លង់អាគារ ព្រមទាំងបទបញ្ញត្តិស្តីពីផែនការរៀបចំក្រុងនិងតំបន់ ។

៥. ថ្លៃឈ្នួលនិងបន្ទុកផ្សេងៗទៀត នៃទីស្ថាននិងលំនៅស្ថាន ដូចមានចែងក្នុងកថាខ័ណ្ឌ១និង២នៃមាត្រា ត្រូវមានកំរិតប្រហាក់ប្រហែលគ្នាទៅនឹងថ្លៃឈ្នួល ឬ បន្ទុកផ្សេងៗទៀត ដែលអនុវត្តជាទូទៅ ចំពោះទីស្ថានប្រហាក់ប្រហែលគ្នា ដែលមិនប្រើប្រាស់ជាទីស្ថានទូត ឬ កុងស៊ុល ។

## មាត្រា ១០
## មន្ត្រីកុងស៊ុលកិត្តិយស

ភាគីចុះកិច្ចសន្យាទាំងសងខាងព្រមព្រៀងនឹងគ្នា ចំពោះរាល់ការតែងតាំងមន្ត្រីកុងស៊ុលកិត្តិយស ។ ភាគីទាំងពីរនឹងពិគ្រោះគ្នា អំពីការរៀបចំបែបបទ ដោយឈរលើបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

## ជំពូក III

## ភាពងាយស្រួល ឯកសិទ្ធិ និង អភ័យឯកសិទ្ធិ

### មាត្រា ១១

### កិច្ចការពារ និង ភាពងាយស្រួលរបស់ប៉ុស្តិ៍កុងស៊ុល និង សមាជិកប៉ុស្តិ៍កុងស៊ុល

១. រដ្ឋម្ចាស់ផ្ទះនឹងផ្តល់រាល់ភាពងាយស្រួលពេញលេញ ដល់ការបំពេញមុខងាររបស់ប៉ុស្តិ៍កុងស៊ុល ។

២. រដ្ឋម្ចាស់ផ្ទះនឹងត្រូវរាប់រកមន្ត្រីកុងស៊ុល ដោយការគោរពរាប់អាន និង ចាត់គ្រប់វិធានការចាំបាច់សមស្រប ដើម្បីទប់ស្កាត់រាល់ការប៉ះពាល់ដល់រូបរាងកាយ សេរីភាព ឬ សេចក្តីថ្លៃថ្នូររបស់គេ និង ការប៉ះពាល់ដល់សមាជិកឯទៀតនៃប៉ុស្តិ៍កុងស៊ុល និង សមាជិកគ្រួសាររបស់បុគ្គលខាងលើ ។

### មាត្រា ១២

### ការប្រើទង់ជាតិ និង សញ្ញាជាតិ

១. រដ្ឋដាក់កុងស៊ុលមានសិទ្ធិប្រើប្រាស់ទង់ជាតិនិងសញ្ញាជាតិរបស់ខ្លួន នៅក្នុងរដ្ឋម្ចាស់ផ្ទះ ស្របតាមបញ្ញត្តិទាំងឡាយនៃមាត្រានេះ ។

២. ទង់ជាតិនៃរដ្ឋដាក់កុងស៊ុលអាចបង្ហូត និង សញ្ញាជាតិរបស់រដ្ឋដាក់កុងស៊ុល រួមមានទាំងអក្សរចារឹកសមស្របជាភាសារដ្ឋដាក់កុងស៊ុល និង ភាសារដ្ឋម្ចាស់ផ្ទះ អាចដាក់នៅនឹងអាគារប្រើប្រាស់ជាប៉ុស្តិ៍កុងស៊ុល និង នៅមាត់ទ្វារចូលនៃអាគារនេះ ក្នុងលំនៅស្ថានរបស់ប្រធានប៉ុស្តិ៍កុងស៊ុល ព្រមទាំងនៅលើមធ្យោបាយធ្វើដំណើរប្រើប្រាស់ ដោយប្រធានប៉ុស្តិ៍កុងស៊ុល ក្នុងការប្រើប្រាស់ផ្លូវការ ។

៣. ក្នុងការប្រើសិទ្ធិ ដូចមានចែងក្នុងមាត្រានេះ រដ្ឋដាក់កុងស៊ុលត្រូវគោរពច្បាប់ បទបញ្ញត្តិ និង តាមទំលាប់របស់រដ្ឋម្ចាស់ផ្ទះ ។

### មាត្រា ១៣

### ភាពមិនអាចរំលោភបំពានបាននៃទីស្ថានកុងស៊ុល

១. ទីស្ថានកុងស៊ុលមិនអាចរំលោភបំពានបាន ដូចដែលបានកំណត់ក្នុងមាត្រានេះ ។

២. អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះគ្មានសិទ្ធិចូលទៅក្នុងផ្នែកណាមួយនៃទីស្ថានកុងស៊ុល ដែលប្រើប្រាស់ជាចំមុខ សំរាប់សេចក្តីត្រូវការនៃការងាររបស់ប៉ុស្តិ៍កុងស៊ុល ដោយគ្មានការយល់ព្រមពីប្រធានប៉ុស្តិ៍កុងស៊ុល ឬ ពីមន្ត្រីណាម្នាក់ដែលលោកចាត់តាំង ឬ ពីប្រធានបេសកកម្មការទូតនៃរដ្ឋដាក់កុងស៊ុល ។ ក៏ប៉ុន្តែការយល់ព្រមរបស់ប្រធានប៉ុស្តិ៍កុងស៊ុល អាចត្រូវបានសន្មតថាបានទទួលក្នុងករណីមានអគ្គីភ័យ ឬ មានមហន្តរាយផ្សេងទៀត ដែលតំរូវចាត់វិធានការការពារជាបន្ទាន់ ។

៣. អនុលោមតាមបទបញ្ញត្តិនៃកថាខ័ណ្ឌ២នៃមាត្រានេះ រដ្ឋម្ចាស់ផ្ទះមានភារកិច្ចពិសេស ត្រូវចាត់រាល់វិធានការសមស្រប ដើម្បីការពារទីស្ថានកុងស៊ុលទប់ស្កាត់ការជ្រៀតចូល ឬការធ្វើឱ្យមានការខូចខាតណាមួយ និង ទប់ស្កាត់ការរំខានដល់សេចក្តីសុខសាន្តរបស់ប៉ុស្តិ៍កុងស៊ុល ឬប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ប៉ុស្តិ៍កុងស៊ុល ។

៤. ទីស្ថានកុងស៊ុល គ្រឿងសង្ហារឹម ទ្រព្យសម្បត្តិ និង មធ្យោបាយធ្វើដំណើររបស់ប៉ុស្តិ៍កុងស៊ុល ត្រូវរួចផុតពីការរឹបអូស សំរាប់បំរើទិសដៅការពារជាតិ និង ការប្រើប្រាស់ជាសាធារណៈ។ ប្រសិនបើការដកហូត ក្នុងគោលដៅបែបនេះ ជាការចាំបាច់នោះ គេត្រូវប្រើឱ្យអស់លទ្ធភាពចាត់គ្រប់វិធានការ ដើម្បីជៀសវាងរំខានដល់ការបំពេញមុខងារកុងស៊ុល និង ត្រូវសងការខាតបង់ជាបន្ទាន់ ពេញថ្លៃ និង ជាក់ស្តែង ដល់រដ្ឋដាក់កុងស៊ុល ។

## មាត្រា ១៤

## ការរួចពន្ធរបស់ទីស្ថានកុងស៊ុល

១. ទីស្ថានកុងស៊ុល និង លំនៅស្ថានប្រធានប៉ុស្តិ៍កុងស៊ុលអាជីព ដែលរដ្ឋដាក់កុងស៊ុល ឬ បុគ្គលណាមួយ ដែលបានបំពេញការងារក្នុងនាមនៃរដ្ឋដាក់កុងស៊ុល ត្រូវជាម្ចាស់កម្មសិទ្ធិ ឬអ្នក ជួល ត្រូវរួចផុតពីរាល់ការបង់ពន្ធនិងអាករគ្រប់បែបយ៉ាង គិតទាំងពន្ធអាករជាតិ តំបន់ ឬខេត្ត ក្រុង ក្រៅពីសោហ៊ុយជាថ្លៃសេវា ដោយឡែកដែលគេបានធ្វើសំរាប់ប៉ុស្តិ៍កុងស៊ុល ។

២. ការរួចពន្ធនិងអាករ ដែលមានចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ នឹងមិនត្រូវអនុវត្តលើពន្ធនិងអាករទាំងឡាយណា ដែលតំរូវឱ្យបង់ចំពោះជនដែលជាប់កិច្ចសន្យាជាមួយនឹងរដ្ឋដាក់កុងស៊ុល ឬ ជាមួយជនជាតំណាងនៃរដ្ឋដាក់កុងស៊ុល យោងតាមច្បាប់និងបទបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ ។

## មាត្រា ១៥

## ភាពមិនអាចរំលោភបំពានបានរបស់សារប៉ាននិងឯកសារកុងស៊ុល

សារប៉ាន និង ឯកសារកុងស៊ុល មិនអាចត្រូវរំលោភបំពានបាននោះឡើយ ទោះជានៅទីណា ឬ កន្លែងណាក៏ដោយ ។

## មាត្រា ១៦

## សេរីភាពក្នុងការធ្វើដំណើរ

វៀរលែងតែមានច្បាប់និងបញ្ញត្តិរបស់ខ្លួនហាមប្រាម ឬ រឹតត្បិតការចេញចូលក្នុងតំបន់ទាំងឡាយណា ដោយមូលហេតុសន្តិសុខជាតិ ឬ សណ្ដាប់ធ្នាប់និងសុវត្ថិភាពសាធារណៈ រដ្ឋម្ចាស់ផ្ទះត្រូវធានាសេរីភាពក្នុងការធ្វើដំណើរនិងដើរហើរ នៅក្នុងដែនដីរបស់ខ្លួនជូនរាល់សមាជិកទាំងអស់របស់ប៉ុស្តិ៍កុងស៊ុល ។ តែនៅគ្រប់កាលៈទេសៈទាំងអស់ រដ្ឋម្ចាស់ផ្ទះត្រូវផ្ដល់ភាពងាយស្រួលដល់មន្ត្រីកុងស៊ុល ក្នុងការបំពេញភារកិច្ចរបស់គេ ។

## មាត្រា ១៧

## សេរីភាពក្នុងការប្រាស្រ័យទាក់ទង

១. រដ្ឋម្ចាស់ផ្ទះអនុញ្ញាត និង ការពារសេរីភាព ក្នុងការប្រាស្រ័យទាក់ទងរបស់ប៉ុស្តិ៍កុងស៊ុល ក្នុងទិសដៅជាផ្លូវការទាំងអស់ ។ ក្នុងការធ្វើទំនាក់ទំនងជាមួយរដ្ឋាភិបាល ជាមួយបណ្ដាស្ថានបេសកកម្មទូតនិងប៉ុស្តិ៍កុងស៊ុលឯទៀត របស់រដ្ឋដាក់កុងស៊ុល ស្ថិតនៅទីណាក៏ដោយ ប៉ុស្តិ៍កុងស៊ុលអាចប្រើគ្រប់មធ្យោបាយទាក់ទងសមស្របទាំងអស់ រួមមាន ហាវីការទូត ឬ កុងស៊ុល ហិបការទូត ឬ កុងស៊ុល សារលិខិតជាអក្សរសំងាត់ ឬ ជាលេខសំងាត់ ។ ក៏ប៉ុន្តែប៉ុស្តិ៍កុងស៊ុលអាចតំលើងនិងប្រើប្រាស់វិទ្យុទាក់ទងបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ ។

២. ការឆ្លើយឆ្លងជាផ្លូវការរបស់ប៉ុស្តិ៍កុងស៊ុល មិនអាចត្រូវរំលោភបំពានបានឡើយ ។

៣. ហិបកុងស៊ុលមិនត្រូវបានបើក ឬ ឃាត់ទុកបានឡើយ ។ ក៏ប៉ុន្តែប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ មានមូលហេតុច្បាស់លាស់ជឿជាក់ថា ហិបកុងស៊ុលមានផ្ទុកវត្ថុផ្សេងទៀត ក្រៅពីលិខិតឆ្លើយឆ្លង ឬ វត្ថុដូចដែលបានចែងក្នុងកថាខ័ណ្ឌ៤នៃមាត្រានេះ អាជ្ញាធរអាចស្នើសុំបើកហិបកុងស៊ុលនោះ នៅចំពោះមុខតំណាងពេញសិទ្ធិរបស់រដ្ឋដាក់កុងស៊ុល ។ ប្រសិនបើតំណាងពេញសិទ្ធិបដិសេធសំណើនេះ ហិបកុងស៊ុលត្រូវបញ្ជូនត្រឡប់ទៅកន្លែងដើមវិញ ។

៤. បណ្ដាកញ្ចប់ដែលរួមជាហិបកុងស៊ុល ត្រូវមានសញ្ញាខាងក្រៅច្បាស់លាស់ បញ្ជាក់ពីលក្ខណៈជាហិបកុងស៊ុល និង ក្នុងនោះមានការផ្ទុកតែសារឆ្លើយឆ្លងនិងឯកសារផ្លូវការ ឬ សំភារៈសំរាប់ប្រើប្រាស់ជាផ្លូវការតែប៉ុណ្ណោះ ។

៥. ហាវីកុងស៊ុលត្រូវមានឯកសារផ្លូវការ បញ្ជាក់ពីឋានៈរបស់ខ្លួន និង ចំនួនកញ្ចប់

ដែលរួមជាហិបកុងស៊ុល ។ ល្គីកណាពុំមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ ហាវីកុងស៊ុលមិនអាចជាពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ ឬ ជាអ្នកស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋម្ចាស់ផ្ទះឡើយ ។ ហាវីកុងស៊ុលនៅក្នុងការបំពេញការងាររបស់ខ្លួន ត្រូវទទួលការការពារពីរដ្ឋម្ចាស់ផ្ទះ ។ ហាវីកុងស៊ុលមានសិទ្ធិមិនអាចត្រូវបានរំលោភបំពានលើរូបកាយ និង មិនត្រូវបានចាប់ឃុំខ្លួន ឬ រឹតត្បិតលើសេរីភាពផ្ទាល់ខ្លួនរបស់គេ តាមរូបភាពណាមួយទៀតឡើយ ។

៦. រដ្ឋដាក់កុងស៊ុល ស្ថានបេសកកម្មទូត និង ប៉ុស្តិ៍កុងស៊ុលរបស់ខ្លួន អាចតែងតាំងហាវីបណ្តោះអាសន្ន ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខ័ណ្ឌ៥នៃមាត្រានេះ ក៏ត្រូវយកមកអនុវត្តផងដែរ ប្លែកតែត្រង់ថា អភ័យឯកសិទ្ធិចែងក្នុងកថាខ័ណ្ឌ៥ នឹងត្រូវអស់ទៅពេលដែលហាវីនេះ បានប្រគល់ហិបកុងស៊ុលជាបន្ទុករបស់ខ្លួន ដល់ដៃអ្នកទទួលរួចហើយ ។

៧. ហិបកុងស៊ុលអាចត្រូវប្រគល់ទៅមេបញ្ជាការនាវា ឬ អាកាសយានពាណិជ្ជកម្មដែលនឹងទៅដល់ចំណត ដែលត្រូវបានអនុញ្ញាតិឱ្យចូលចត ។ មេបញ្ជាការនេះ ត្រូវមានឯកសារផ្លូវការ បញ្ជាក់ពីចំនួនកញ្ចប់ដែលរួមជាហិបកុងស៊ុល ប៉ុន្តែខ្លួនគេមិនត្រូវចាត់ទុកជាហាវីកុងស៊ុលទេ ។ ដោយមានការសំរបសំរួលជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែង ប៉ុស្តិ៍កុងស៊ុលនឹងបញ្ជូនតំណាងម្នាក់ដែលជាសមាជិករបស់ខ្លួន ទៅទទួលយកហិបនោះដោយផ្ទាល់និងដោយសេរីពីមេបញ្ជាការនាវា ឬ អាកាសយាន ឬ ក៏យកហិបទៅប្រគល់ជូនមេបញ្ជាការនោះ តាមបែបបទដូចគ្នា ។

## មាត្រា ១៨
## សិទ្ធិមិនអាចរំលោភបំពានលើរូបរាងកាយមន្ត្រីកុងស៊ុល
## និងការជូនពត៌មានពីបណ្តឹងចោទប្រកាន់លើសមាជិកបុគ្គលិកកុងស៊ុល

១. មន្ត្រីកុងស៊ុលមិនអាចត្រូវចាប់ខ្លួន ឬ ឃុំខ្លួន លើកលែងតែក្នុងករណីមានបទឧក្រិដ្ឋធ្ងន់ធ្ងរ និង អនុលោមតាមសេចក្តីសំរេចពីអាជ្ញាធរមានសមត្ថកិច្ចរបស់តុលាការ ។

២. ក្រៅពីករណីដូចកំណត់នៅក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ មន្ត្រីកុងស៊ុលមិនអាចត្រូវដាក់ពន្ធនាគារ ឬ ត្រូវបានរឹតត្បិតក្នុងរូបភាពណាផ្សេងទៀតលើសេរីភាពផ្ទាល់ខ្លួន លើកលែងតែការអនុវត្តន៍សេចក្តីសំរេចជាស្ថាពររបស់តុលាការ ។

៣. ប្រសិនបើមានការជំនុំជំរះក្តី ពីបទព្រហ្មទណ្ឌលើមន្ត្រីកុងស៊ុលណាម្នាក់ មន្ត្រីកុងស៊ុលនោះ ត្រូវបង្ហាញខ្លួននៅមុខអាជ្ញាធរមានសមត្ថកិច្ច ។ ទោះជាយ៉ាងនេះក្តី នីតិវិធីនេះត្រូវធ្វើឡើងដោយមានការគោរពដល់មន្ត្រីនោះ យោងទៅតាមតួនាទីផ្លូវការរបស់គេ ធ្វើយ៉ាងណាឱ្យរំខាន

តិចបំផុតដល់ការបំពេញមុខងារកុងស៊ុល លើកលែងតែករណីដូចចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ ។ ក្នុងសភាពការណ៍ ដូចបានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ នៅពេលមានការចាំបាច់ត្រូវឃាត់ខ្លួនមន្ត្រីកុងស៊ុលណាម្នាក់ នីតិវិធីដែលធ្វើទៅលើមន្ត្រីនោះ ត្រូវធ្វើឡើងដោយរួសរាន់បំផុត ។

៤. ក្នុងករណីមានការចាប់ខ្លួន ឬ ឃុំខ្លួនសមាជិកបុគ្គលិកកុងស៊ុល ឬ ក្នុងករណីមានការចោទប្រកាន់ជំនុំជំរះក្តីពីបទឧក្រិដ្ឋលើអ្នកទាំងនោះ រដ្ឋម្ចាស់ផ្ទះត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ប្រធានប៉ុស្តិ៍កុងស៊ុល ។ ប្រសិនបើប្រធានប៉ុស្តិ៍កុងស៊ុលខ្លួនឯងជាកម្មវត្ថុនៃវិធានការបែបនេះ រដ្ឋម្ចាស់ផ្ទះត្រូវជូនដំណឹងតាមផ្លូវទូត ទៅរដ្ឋដាក់កុងស៊ុល ។

## មាត្រា ១៩

## អភ័យឯកសិទ្ធិត្រូវរួចផុតពីយុត្តាធិការរបស់តុលាការ

១. មន្ត្រីកុងស៊ុលនិងនយោជិកកុងស៊ុល នឹងមិនស្ថិតនៅក្រោមអំណាចនៃយុត្តាធិការរបស់អាជ្ញាធរតុលាការនិងរដ្ឋបាលរដ្ឋម្ចាស់ផ្ទះ ចំពោះអំពើដែលអ្នកទាំងនោះធ្វើក្នុងការបំពេញមុខងារកុងស៊ុល ។

២. ក៏ប៉ុន្តែបទបញ្ញត្តិនៃកថាខណ្ឌ១នៃមាត្រានេះ នឹងមិនអនុវត្តទេ ចំពោះបទចោទប្រកាន់ផ្នែករដ្ឋប្បវេណី ដែល :

ក- កើតឡើងពីកិច្ចសន្យា ធ្វើឡើងដោយមន្ត្រីកុងស៊ុល ឬ នយោជិកកុងស៊ុល ដែលក្នុងនោះ គេពុំបានបញ្ជាក់ច្បាស់លាស់ ឬ ពុំបានចែងច្បាស់លាស់ថា ជាភ្នាក់ងារក្នុងនាមរដ្ឋដាក់កុងស៊ុល ឬក៏

ខ- កើតឡើងពីបណ្តឹងក្តីរបស់ភាគីទីពណាមួយ ទារសំណងការខូចខាត បណ្តាលមកពីគ្រោះថ្នាក់ ដែលបង្កឡើងដោយយានជំនិះ នាវា ឬ យន្តហោះ នៅក្នុងទឹកដីរដ្ឋម្ចាស់ផ្ទះ ។

## មាត្រា ២០

## ភារកិច្ចផ្តល់សក្ខីកម្ម

១. សមាជិកប៉ុស្តិ៍កុងស៊ុល អាចត្រូវកោះហៅ ឱ្យឡើងធ្វើជាកសិណសាក្សី នៅក្នុងសវនាការតុលាការ ឬ នីតិវិធីរដ្ឋបាល ។ នយោជិកកុងស៊ុល ឬ សមាជិកបុគ្គលិកបំរើការងារមិនត្រូវបដិសេធឡើងធ្វើជាកសិណសាក្សីទេ លើកលែងតែក្នុងករណីចែងនៅក្នុងកថាខណ្ឌ៣នៃមាត្រានេះ

។ ប្រសិនបើមន្ត្រីកុងស៊ុលបដិសេធ មិនព្រមធ្វើជាកសិណសាក្សី គ្មានវិធានការបង្ខិតបង្ខំ ឬ ទោសពៃរ៍ណាមួយ នឹងត្រូវអនុវត្តទៅលើមន្ត្រីនោះឡើយ ។

២. អាជ្ញាធរដែលត្រូវការចំលើយជាសាក្សីពីមន្ត្រីកុងស៊ុល ត្រូវជៀសវាងជ្រៀតជ្រែកដល់ការបំពេញមុខងាររបស់មន្ត្រីកុងស៊ុល ។ ក្នុងលក្ខខ័ណ្ឌដែលអាចធ្វើបាន អាជ្ញាធរអាចទៅយកភស្តុតាងទាំងនោះ នៅលំនៅស្ថានរបស់មន្ត្រីនោះ ឬ នៅប៉ុស្តិ៍កុងស៊ុល ឬ ក៏ទទួលចំលើយសាក្សីពីមន្ត្រីនោះ ជាលាយលក្ខណ៍អក្សរ ។

៣. សមាជិកនៃប៉ុស្តិ៍កុងស៊ុល មិនមានកាតព្វកិច្ចត្រូវផ្តល់ភស្តុតាងអំពីបញ្ហាដែលពាក់ព័ន្ធ ដល់ការបំពេញមុខងាររបស់ខ្លួន ឬ បង្ហាញលិខិតឆ្លើយឆ្លង និង ឯកសារផ្លូវការ ពាក់ព័ន្ធទៅនឹងបញ្ហាខាងលើនេះ ។ សមាជិកប៉ុស្តិ៍កុងស៊ុលមានសិទ្ធិផងដែរ ក្នុងការបដិសេធមិនធ្វើជាកសិណសាក្សី ក្នុងនាមជាសាក្សីឯកទេស ស្តីពីច្បាប់និងបទបញ្ញត្តិរបស់រដ្ឋដាក់កុងស៊ុល ។

## មាត្រា ២១

## ការបដិសេធចោលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ

១. រដ្ឋដាក់កុងស៊ុលអាចបដិសេធផ្នែកខ្លះនៃបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងមាត្រា ១៨ ១៩ និង ២០ នៃអនុសញ្ញានេះ ចំពោះសមាជិកណាម្នាក់នៃប៉ុស្តិ៍កុងស៊ុល ។

២. ការបដិសេធនៅគ្រប់ករណីទាំងអស់ ត្រូវធ្វើដោយជាក់លាក់ លើកលែងតែក្នុងករណីដូចចែងក្នុងកថាខ័ណ្ឌ៣នៃមាត្រានេះ ហើយការបដិសេធនេះ ត្រូវបញ្ជូនទៅរដ្ឋម្ចាស់ផ្ទះ ជាលាយលក្ខណ៍អក្សរ ។

៣. ប្រសិនបើមន្ត្រីកុងស៊ុល ឬ និយោជិកកុងស៊ុលណាម្នាក់ ចេញមុខធ្វើបណ្តឹងក្តីលើបញ្ហាណាមួយ ដែលខ្លួនអាចទទួលអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការរបស់តុលាការ ស្របតាមមាត្រា ១៩នៃអនុសញ្ញានេះ ជននោះមិនអាចលើកមកសំអាងពីអភ័យឯកសិទ្ធិផុតពីយុត្តាធិការរបស់តុលាការចំពោះពាក្យបណ្តឹងតបវិញ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបណ្តឹងដើមឡើយ ។

៤. ការបដិសេធអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការរបស់តុលាការ ចំពោះការជំរះក្តីផ្នែករដ្ឋប្បវេណី ឬ រដ្ឋបាល មិនមានន័យថា ជាការបដិសេធវិធានការអនុវត្តសាលក្រមតុលាការផងដែរ ។ ដើម្បីអាចអនុវត្តសាលក្រមខាងលើបាន ចាំបាច់ត្រូវមានលិខិតបដិសេធមួយ ដាច់ដោយឡែកទៀត ។

## មាត្រា ២២
## ការរួចផុតពីការចុះស្ថិតិជនបរទេសនិងលិខិតអនុញ្ញាតិស្នាក់នៅ

១. មន្ត្រីកុងស៊ុល នយោជិកកុងស៊ុល និង សមាជិកគ្រួសាររបស់គេ ត្រូវរួចផុតពីកាតព្វកិច្ចចុះក្នុងបញ្ជីជនបរទេសនិងលិខិតអនុញ្ញាតិស្នាក់នៅ ដូចដែលច្បាប់និងបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ បានកំណត់ចំពោះជនបរទេស ។

២. បទបញ្ញត្តិនៃកថាខ័ណ្ឌ១របស់មាត្រានេះ នឹងមិនអនុវត្តចំពោះនយោជិកកុងស៊ុល ដែលមិនមែនជានយោជិកអចិន្ត្រៃយ៍របស់រដ្ឋដាក់កុងស៊ុល ឬ ជនដែលប្រកបមុខរបរមានកំរៃផ្ទាល់ខ្លួន នៅក្នុងរដ្ឋម្ចាស់ផ្ទះ ឬ ចំពោះសមាជិកគ្រួសារណាមួយរបស់នយោជិកនោះ ។

## មាត្រា ២៣
## ការរួចផុតពីការកាន់លិខិតអនុញ្ញាតិការងារ

១. ចំពោះសេវាដែលខ្លួនធ្វើជូនរដ្ឋដាក់កុងស៊ុល បណ្តាសមាជិកកុងស៊ុលនឹងត្រូវរួចផុតពីកាតព្វកិច្ចកាន់លិខិតអនុញ្ញាតិការងារ ដែលកំណត់ដោយច្បាប់និងបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ ស្តីពីការប្រើកំលាំងពលកម្មបរទេស ។

២. សមាជិកបុគ្គលិកឯកជនរបស់មន្ត្រីកុងស៊ុល និង នយោជិកកុងស៊ុល ត្រូវរួចផុតពីកាតព្វកិច្ចចែងនៅក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ ប្រសិនបើជនទាំងនេះ មិនប្រកបមុខរបរមានកំរៃណាផ្សេងទៀត នៅក្នុងរដ្ឋម្ចាស់ផ្ទះ ។

## មាត្រា ២៤
## ការរួចផុតពីរបបសន្តិសុខសង្គម

១. ក្រៅពីបញ្ញត្តិក្នុងកថាខ័ណ្ឌ៣នៃមាត្រានេះ សមាជិកប៉ុស្តិ៍កុងស៊ុល និង សមាជិករបស់គេ ត្រូវរួចផុតពីបទបញ្ញត្តិស្តីពីសន្តិសុខសង្គម ដែលជាធរមាននៅក្នុងរដ្ឋម្ចាស់ផ្ទះ ចំពោះការងារដែលគេធ្វើជូនរដ្ឋដាក់កុងស៊ុល ។

២. ការរួចផុតចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ នឹងត្រូវអនុវត្តផងដែរ ដល់សមាជិកបុគ្គលិកឯកជន ដែលធ្វើការបំរើសមាជិកប៉ុស្តិ៍កុងស៊ុលតែមួយមុខ ក្នុងលក្ខខ័ណ្ឌដែល :

ក- ជនទាំងនេះពុំមែនជាពលរដ្ឋ ឬ មានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ និង

ខ- ជនទាំងនេះស្ថិតនៅក្រោមរបបសន្តិសុខសង្គមជាធរមាននៅក្នុងរដ្ឋដាក់កុងស៊ុល ឬ ប្រទេសទីពណាមួយ ។

៣. សមាជិកប៉ុស្តិ៍កុងស៊ុល ដែលប្រើប្រាស់ជនដែលមិនស្ថិតនៅក្រោមការរួចផុតចែង ក្នុងកថាខ័ណ្ឌ២នៃមាត្រានេះ ត្រូវប្រតិបត្តិតាមកាតព្វកិច្ច ដែលបទបញ្ញត្តិស្តីពីសន្តិសុខសង្គមរបស់រដ្ឋម្ចាស់ផ្ទះ តំរូវចំពោះនយោជិកទាំងឡាយ ។

៤. ការរួចផុតចែងក្នុងកថាខ័ណ្ឌ១និង២នៃមាត្រានេះ នឹងមិនរារាំងការចូលរួមដោយស្ម័គ្រចិត្ត ក្នុងប្រព័ន្ធសន្តិសុខសង្គមរបស់រដ្ឋម្ចាស់ផ្ទះ ក្នុងករណីដែលខ្លួនបានអនុញ្ញាតិឱ្យមានការចូលរួមនេះ ។

## មាត្រា ២៩

## ការរួចផុតពីពន្ធអាករ

១. មន្ត្រីកុងស៊ុល និង នយោជិកកុងស៊ុល និង សមាជិកគ្រួសាររបស់គេ ត្រូវរួចផុតពីពន្ធអាករជាតិ តំបន់ ឬ ខេត្តក្រុង លើរូបរាងកាយនិងទ្រព្យសម្បត្តិ លើកលែងតែ :

ក- ពន្ធមិនចំពោះ ដែលធម្មតាត្រូវបានបញ្ចូលនៅក្នុងតំលៃទំនិញ ឬ សេវា

ខ- ពន្ធអាករលើអចលនវត្ថុឯកជន ស្ថិតនៅក្នុងរដ្ឋម្ចាស់ផ្ទះ ក្រៅពីបញ្ញត្តិនៃមាត្រា១៤

គ- អាករ ឬ បន្ទុកប្រហាក់ប្រហែលគ្នានោះ ដែលត្រូវមានលើទ្រព្យសម្បត្តិមរតក ឬ ការទទួលមរតក ឬ ការផ្ទេរមរតក នៅក្នុងរដ្ឋម្ចាស់ផ្ទះ ក្រៅពីបញ្ញត្តិក្នុងកថាខ័ណ្ឌ២នៃមាត្រា២៧

ឃ- ពន្ធអាករ និង ពន្ធលើប្រាក់ចំណូលឯកជន រួមទាំងប្រាក់ចំណេញពីធនធានដែលមានប្រភពក្នុងរដ្ឋម្ចាស់ផ្ទះ និង ពន្ធអាករមូលធនដែលវិនិយោគក្នុងវិស័យពាណិជ្ជកម្ម ឬ ហិរញ្ញវត្ថុនៅក្នុងរដ្ឋម្ចាស់ផ្ទះ

ង- បន្ទុកលើសេវាកម្មមានកំរៃ

ច- អាករចុះបញ្ជី ក្រឡាបញ្ជី ឬ ពន្ធបញ្ជាំខ្ចី និង តែមប្រើ ស្របតាមបញ្ញត្តិនៃមាត្រា ១៤ ។

២. សមាជិកបុគ្គលិកបំរើការរបស់ប៉ុស្តិ៍កុងស៊ុលទាំងអស់ ត្រូវបានរួចពន្ធអាករនៅលើប្រាក់បៀវត្ស ដែលគេទទួលបានលើការងាររបស់ខ្លួន ។

៣. សមាជិកនៃប៉ុស្តិ៍កុងស៊ុលណា ដែលជួលមនុស្សដែលមិនបានរួចពន្ធលើចំណូលនោះ ត្រូវគោរពកាតព្វកិច្ច ដែលច្បាប់និងច្បាប់បញ្ញត្តិរបស់រដ្ឋនោះ កំណត់ទៅលើការយកពន្ធលើចំណូល។

## មាត្រា ២៦
## ការរួចផុតពីពន្ធគយ និង ការត្រួតពិនិត្យគយ

១. ស្របតាមច្បាប់និងបញ្ញត្តិដែលបានអនុម័តហើយ រដ្ឋម្ចាស់ផ្ទះនឹងអនុញ្ញាតិឱ្យនាំចូល និងនាំចេញ និង រួចផុតពីពន្ធអាករគយទាំងអស់ និង បន្ទុកពាក់ព័ន្ធទាំងឡាយទៀត (ក្រៅពីសោហ៊ុយថ្លៃរក្សាទុកក្នុងឃ្លាំង សោហ៊ុយដឹកជញ្ជូន និង សេវាប្រហាក់ប្រហែលផ្សេងទៀត) លើ :

ក- សំភារៈប្រើប្រាស់ជាផ្លូវការរបស់ប៉ុស្តិ៍កុងស៊ុល

ខ- សំភារៈសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួននៃមន្ត្រីកុងស៊ុល ឬ សមាជិកគ្រួសាររបស់គេ រួមទាំងសំភារៈសំរាប់ការតាំងទីជាលើកដំបូងរបស់គេ ។ គ្រឿងឧបភោគនិងបរិភោគ នឹងមិនត្រូវឱ្យលើសពីបរិមាណចាំបាច់ សំរាប់ការប្រើប្រាស់ផ្ទាល់របស់បុគ្គលពាក់ព័ន្ធ ។

២. និយោជិកកុងស៊ុលនឹងទទួលបុព្វសិទ្ធិនិងការរួចផុត ដូចចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ ចំពោះសំភារៈនាំចូល នៅពេលមកតាំងទីជាលើកដំបូង ។

៣. ហិបឥវ៉ាន់ផ្ទាល់ខ្លួន ដែលមន្ត្រីកុងស៊ុល និង សមាជិកគ្រួសាររបស់គេនាំមកតាមខ្លួន ត្រូវរួចផុតពីការត្រួតពិនិត្យរបស់គយ ។ ហិបឥវ៉ាន់អាចត្រូវត្រួតពិនិត្យបាន លុះត្រាតែមានមូលហេតុមុតមាំដែលឱ្យជឿជាក់ថា ក្នុងហិបនោះមានវត្ថុផ្សេងក្រៅពីវត្ថុចែងនៅក្នុងវាក្យខណ្ឌ(ខ) កថាខ័ណ្ឌ១នៃមាត្រានេះ ឬ វត្ថុដែលការនាំចូលឬនាំចេញ ត្រូវហាមឃាត់ដោយច្បាប់និងបញ្ញាត្តិរបស់រដ្ឋម្ចាស់ផ្ទះ ឬ ក៏វត្ថុដែលស្ថិតនៅក្រោមច្បាប់និងបញ្ញាត្តិរបស់ចត្តាឡីស័ករបស់រដ្ឋនេះ ការត្រួតពិនិត្យត្រូវធ្វើឡើងចំពោះមុខមន្ត្រីកុងស៊ុល ឬ សមាជិកគ្រួសារដែលពាក់ព័ន្ធ ។

## មាត្រា ២៧
## ទ្រព្យមរតករបស់សមាជិកប៉ុស្តិ៍កុងស៊ុល ឬ សមាជិកគ្រួសាររបស់អ្នកទាំងនោះ

នៅក្នុងករណីសមាជិកប៉ុស្តិ៍កុងស៊ុល ឬ សមាជិកនៃគ្រួសាររបស់គេទទួលមរណៈភាព រដ្ឋម្ចាស់ផ្ទះ :

១. នឹងអនុញ្ញាតឱ្យនាំចេញនូវចលនវត្ថុរបស់សព លើកលែងតែទ្រព្យសម្បត្តិណាដែលរកបាននៅក្នុងរដ្ឋម្ចាស់ផ្ទះ ដែលការនាំចេញត្រូវហាមឃាត់ នៅពេលដែលជននោះទទួលមរណៈភាព ។ ក្នុងករណីនេះ ទ្រព្យសម្បត្តិដែលគេហាមឃាត់មិនឱ្យនាំចេញ នឹងត្រូវផ្ទេរជូនទៅប៉ុស្តិ៍កុងស៊ុលនៃរដ្ឋដាក់កុងស៊ុល ។

៦ល

២. មិនត្រូវហូតអាករជាតិ តំបន់ ឬ ខេត្តក្រុង លើមរតក ការស្នង ឬ ការទទួលមរតកនិងអាករ លើការផ្ទេរសម្បត្តិចលនវត្ថុដែលមានក្នុងរដ្ឋម្ចាស់ផ្ទះ ដោយសារតែមានវត្តមានរបស់សព ដែលជាសមាជិកប៉ុស្តិ៍កុងស៊ុល ឬ សមាជិកគ្រួសារនៃសមាជិកប៉ុស្តិ៍កុងស៊ុល នៅក្នុងរដ្ឋនោះ ។

## មាត្រា ២៨
## ការរួចផុតពីសេវាកម្មផ្ទាល់ខ្លួន និង ពីវិភាគទាន

រដ្ឋជាម្ចាស់ផ្ទះត្រូវលើកលែង សមាជិកប៉ុស្តិ៍កុងស៊ុល និង សមាជិកគ្រួសាររបស់គេពីរាល់ការផ្តល់ជាកំលាំងបំរើផ្ទាល់ខ្លួន និង សាធារណៈគ្រប់បែបយ៉ាង ក៏ដូចជាកាតព្វកិច្ចយោធាដូចជាកាតព្វកិច្ចទាំងឡាយ ដែលពាក់ព័ន្ធជាមួយកំណែនយោធា វិភាគទានយោធា និង កាតព្វកិច្ចទទួលឱ្យស្នាក់អាស្រ័យ ។

## មាត្រា ២៩
## ការចាប់ផ្តើម និង ការបញ្ចប់នៃបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ

១. រាល់សមាជិកប៉ុស្តិ៍កុងស៊ុលត្រូវទទួលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ ចាប់ពីពេលដែលគេចូលក្នុងទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ ដើម្បីមកកាន់មុខតំណែងរបស់ខ្លួន ឬ ប្រសិនបើបានមកដល់ទឹកដីនោះរួចហើយ គឺចាប់ពីពេលដែលគេបានចូលបំពេញភារកិច្ចរបស់ខ្លួននៅក្នុងប៉ុស្តិ៍កុងស៊ុល ។

២. សមាជិកគ្រួសាររបស់សមាជិកប៉ុស្តិ៍កុងស៊ុល និង សមាជិកបុគ្គលិកឯកជនរបស់សមាជិកប៉ុស្តិ៍កុងស៊ុល នឹងទទួលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ ចាប់ពីកាលបរិច្ឆេទណាមួយចុងក្រោយបង្អស់នៃកាលបរិច្ឆេទតទៅនេះ ថ្ងៃដែលសមាជិកប៉ុស្តិ៍កុងស៊ុលបានទទួលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ស្របតាមកថាខ័ណ្ឌទី១នៃមាត្រានេះ ឬ ថ្ងៃដែលគេបានចូលមកដល់រដ្ឋជាម្ចាស់ផ្ទះ ឬ ថ្ងៃដែលគេបានក្លាយជាសមាជិកនៃក្រុមគ្រួសារនោះ ឬ សមាជិកបុគ្គលិកឯកជននោះ ។

៣. នៅពេលដែលមុខងាររបស់សមាជិកប៉ុស្តិ៍កុងស៊ុលបានត្រូវបញ្ចប់ រាល់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់គេ ក៏ដូចជារបស់សមាជិកនៃក្រុមគ្រួសារគេ ឬ របស់សមាជិកបុគ្គលិកឯកជនរបស់គេ ត្រូវបញ្ចប់ជាធម្មតានៅកាលបរិច្ឆេទណាមួយ ដែលឆាប់ជាងគេបង្អស់នៃកាលបរិច្ឆេទដូចតទៅ ពេលដែលជនទាំងអស់នោះចាកចេញពីរដ្ឋជាម្ចាស់ផ្ទះ ឬ ពេលផុតកំណត់នៃរយៈពេលមួយ

សមស្រប សំរាប់ការចាកចេញដំណើរ ប៉ុន្តែបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងនោះ នឹងនៅតែមានរហូតពេលនោះ ទោះបីក្នុងករណីមានវិវាទដោយអាវុធក្តី ។ ក្នុងករណីដែលជនដូចមានចែងក្នុងកថាខ័ណ្ឌ ២នៃមាត្រានេះ ពួកគេត្រូវអស់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិទាំងនេះ នៅពេលដែលខ្លួនឈប់ជាសមាជិកក្នុងបន្ទុកគ្រួសារ ឬ ឈប់បំពីការឱ្យសមាជិកប៉ុស្តិ៍កុងស៊ុល ប៉ុន្តែប្រសិនបើជនទាំងនោះមានបំណងចាកចេញពីរដ្ឋជាម្ចាស់ផ្ទះ ក្នុងរយៈពេលសមស្របណាមួយ បន្ទាប់ពីនោះមកបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ពួកគេ នឹងនៅតែមានរហូតដល់ពេល នៃការចេញដំណើររបស់ជនទាំងនោះ ។

៤. ប៉ុន្តែចំពោះអំពើទាំងឡាយដែលមន្ត្រីកុងស៊ុល ឬ និយោជិកកុងស៊ុលប្រព្រឹត្តក្នុងការបំពេញមុខងាររបស់គេ អភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការតុលាការ នឹងស្ថិតនៅជារៀងរហូតដោយគ្មានពេលកំណត់ ។

៥. ក្នុងករណីមានមរណៈភាពនៃសមាជិកប៉ុស្តិ៍កុងស៊ុល សមាជិកគ្រួសារនៃជននោះ នឹងនៅតែទទួលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ដែលផ្តល់ចំពោះគេរហូតដល់កាលបរិច្ឆេទណាមួយ ដែលឆាប់បំផុតនៃកាលបរិច្ឆេទដូចតទៅ ពេលគេចាកចេញពីរដ្ឋជាម្ចាស់ផ្ទះ ឬ រហូតដល់ពេលផុតកំណត់នៃរយៈកាលមួយសមស្រប ដែលទុកសំរាប់ការចេញដំណើររបស់គេ ។

## មាត្រា ៣០
## ការគោរពច្បាប់ និង បទបញ្ញត្តិនៃរដ្ឋជាម្ចាស់ផ្ទះ

១. បុគ្គលទាំងឡាយដែលបានទទួលអភ័យឯកសិទ្ធិនិងបុព្វសិទ្ធិ ត្រូវមានកាតព្វកិច្ចគោរពច្បាប់និងបទបញ្ញត្តិទាំងឡាយនៃរដ្ឋជាម្ចាស់ផ្ទះ ដោយពុំមានបាត់បង់បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ខ្លួន ។ បុគ្គលទាំងនេះ ត្រូវមានភារកិច្ចមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងនៃរដ្ឋជាម្ចាស់ផ្ទះផងដែរ ។

២. ទីស្នាក់ប៉ុស្តិ៍កុងស៊ុល មិនត្រូវប្រើប្រាស់ក្នុងលក្ខណៈណាមួយដែលប្រាសចាកពីក្របខ័ណ្ឌនៃមុខងារកុងស៊ុលឡើយ ។

៣. បញ្ញាត្តិទាំងឡាយរបស់កថាខ័ណ្ឌទី២នៃមាត្រានេះ មិនលុបបំបាត់លទ្ធភាពតាំងបង្កើតការិយាល័យនៃស្ថាប័នផ្សេងទៀត ឬ ទីភ្នាក់ងារដទៃទៀត ក្នុងចំណែកណាមួយនៃអាគារដែលប៉ុស្តិ៍កុងស៊ុលតាំងនៅ ល្គឹកណាអាគារដែលប្រើប្រាស់ជាការិយាល័យ ឬ ទីភ្នាក់ងារទាំងនោះត្រូវបានខ័ណ្ឌផ្តាច់ពីអាគារដែលប្រើប្រាស់ដោយប៉ុស្តិ៍កុងស៊ុល ។ ក្នុងករណីនេះ ការិយាល័យខាងលើមិនត្រូវចាត់ទុកជា ផ្នែកមួយនៃទីស្នាក់កុងស៊ុល ក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះទេ ។

## មាត្រា ៣១

## ការធានារ៉ាប់រងចំពោះការខូចខាតដល់ភាគីទីបី

រាល់សមាជិកនៃប៉ុស្តិ៍កុងស៊ុល ត្រូវប្រតិបត្តិតាមការកំណត់របស់ច្បាប់និងបទបញ្ញត្តិរបស់រដ្ឋជាម្ចាស់ផ្ទះ ស្តីពីការធានារ៉ាប់រងដល់ការខូចខាតរបស់ភាគីផងទៃទៀត ដែលបណ្តាលមកពីការប្រើប្រាស់យានជំនិះ ជលយាន ឬ អាកាសយាន ។

## មាត្រា ៣២

## បទបញ្ញត្តិពិសេស ស្តីពីមុខរបររកកំរៃឯកជន

១. មន្ត្រីកុងស៊ុលអាជីពនឹងមិនត្រូវធ្វើសកម្មភាពវិជ្ជាជីវៈពាណិជ្ជកម្ម ក្នុងរដ្ឋជាម្ចាស់ផ្ទះ ដើម្បីរកកំរៃផ្ទាល់ខ្លួនឡើយ ។

២. បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិដែលត្រូវបានចែងក្នុងជំពូកនេះ នឹងមិនត្រូវផ្តល់ជូនចំពោះ :

ក/. ចំពោះនយោជិកកុងស៊ុល ឬ សមាជិកនៃបុគ្គលិកបំរើការ ដែលប្រកបមុខរបររកកំរៃឯកជនក្នុងរដ្ឋជាម្ចាស់ផ្ទះ ។

ខ/. សមាជិកគ្រួសារទាំងអស់របស់ជនដូចមានចែងក្នុងវាក្យខ័ណ្ឌ(ក) នៃកថាខ័ណ្ឌនេះ ឬ សមាជិកនៃបុគ្គលិកឯកជនរបស់ជននោះទេ ។

គ/. បណ្តាសមាជិកគ្រួសាររបស់សមាជិកប៉ុស្តិ៍កុងស៊ុល ដែលខ្លួនគេផ្ទាល់បានប្រកបមុខរបររកកំរៃឯកជនណាមួយក្នុងរដ្ឋជាម្ចាស់ផ្ទះ ។

## មាត្រា ៣៣

## ពលរដ្ឋ ឬ ជនមានទីលំនៅអចិន្ត្រៃយ៍នៃរដ្ឋជាម្ចាស់ផ្ទះ

១. លើកលែងតែក្នុងករណីដែលរដ្ឋម្ចាស់ផ្ទះ ផ្តល់ឱ្យភាពងាយស្រួលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិបន្ថែមទៀត មន្ត្រីប៉ុស្តិ៍កុងស៊ុលដែលជាពលរដ្ឋ ឬ ជាជនមានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋនោះ នឹង បានទទួលតែអភ័យឯកសិទ្ធិរួចពីយុត្តាធិការតុលាការ និង សិទ្ធិមិនត្រូវគេរំលោភបំពានលើរូបរាងកាយ តែចំពោះអំពើជាផ្លូវការដែលបានធ្វើក្នុងការបំពេញមុខងាររបស់ខ្លួន និង បុព្វសិទ្ធិ ចែង

ក្នុងកថាខ័ណ្ឌ៣នៃមាត្រា២០ ។ ពាក់ព័ន្ធដល់មន្ត្រីប៉ុស្តិ៍កុងស៊ុលខាងលើនេះ រដ្ឋជាម្ចាស់ផ្ទះត្រូវមានកាតព្វកិច្ចដូចបានកំណត់ក្នុងមាត្រា១៨ ។

២. សមាជិកផ្សេងទៀតនៃប៉ុស្តិ៍កុងស៊ុលដែលជាពលរដ្ឋ ឬ ជនមានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ និងសមាជិកទាំងឡាយនៃក្រុមគ្រួសារគេ ព្រមទាំងសមាជិកគ្រួសាររបស់មន្ត្រីកុងស៊ុលដូចមានចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ នឹងទទួលបាននូវភាពងាយស្រួលបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិតែក្នុងកំរិតណាមួយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ជូន ។ រាល់សមាជិកគ្រួសារនៃប៉ុស្តិ៍កុងស៊ុលទាំងនោះ និងបណ្តាសមាជិកនៃបុគ្គលិកឯកជនដែលជាពលរដ្ឋ ឬ ជាជនមានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋជាម្ចាស់ផ្ទះ នឹងត្រូវទទួលបានដូចគ្នានូវភាពងាយស្រួលផ្សេងៗ, បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ក្នុងកំរិតណាមួយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ជូន ។ ប៉ុន្តែរដ្ឋជាម្ចាស់ផ្ទះនឹងត្រូវធ្វើការជំនុំជំរះលើជនទាំងនោះ ដោយធ្វើយ៉ាងណាកុំឱ្យរាំងស្ទះហួសប្រមាណដល់ការបំពេញមុខងារនៃប៉ុស្តិ៍កុងស៊ុល ។

## ជំពូក IV

## មុខងារកុងស៊ុល

## មាត្រា ៣៩

## ការបំពេញមុខងារកុងស៊ុលដោយស្ថានបេសកកម្មការទូត

១. មុខងារកុងស៊ុលត្រូវបំពេញដោយប៉ុស្តិ៍កុងស៊ុល ។ អនុលោមតាមបញ្ញត្តិនៃអនុសញ្ញានេះ មុខងារកុងស៊ុលក៏អាចត្រូវបំពេញដោយស្ថានបេសកកម្មការទូតផងដែរ ។

២. បណ្តាបញ្ញត្តិនៃអនុសញ្ញានេះ ក៏ត្រូវអនុវត្តផងដែរ ទៅលើការបំពេញមុខងារកុងស៊ុល ដោយស្ថានបេសកកម្មការទូតផងដែរ ទៅតាមវិសាលភាពនៃបរិបទនេះ ។

៣. ឈ្មោះនៃសមាជិករបស់ស្ថានបេសកកម្មការទូត ដែលទទួលភារកិច្ចឱ្យបំពេញមុខងារកុងស៊ុលរបស់ស្ថានបេសកកម្មនេះ ត្រូវបញ្ជូនមកក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ឬ មកអាជ្ញាធរ ដែលចាត់តាំងដោយក្រសួងនោះ ។

៤. ក្នុងពេលបំពេញមុខងារកុងស៊ុល ស្ថានបេសកកម្មការទូត អាចធ្វើទំនាក់ទំនងជាមួយ :

ក/ អាជ្ញាធរមានសមត្ថកិច្ចមូលដ្ឋានក្នុងមណ្ឌលកុងស៊ុល

ខ/ អាជ្ញាធរមានសមត្ថកិច្ចកណ្តាលនៃរដ្ឋជាម្ចាស់ផ្ទះ ប្រសិនបើច្បាប់, បទបញ្ញត្តិផ្សេងៗ និងទំលាប់នៃរដ្ឋជាម្ចាស់ផ្ទះ ឬ កិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធណាមួយ អនុញ្ញាត

ឱ្យធ្វើ ។

៥. បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់បណ្តាសមាជិកនៃស្ថានបេសកកម្មការទូត ដូចមានចែងក្នុងកថាខ័ណ្ឌ៣នៃមាត្រានេះ នឹងត្រូវបន្តស្ថិតក្រោមក្រិតក្រមនៃច្បាប់អន្តរជាតិ ស្តីពីទំនាក់ទំនងការទូត ។

## មាត្រា ៣៥

## ការបំពេញមុខងារកុងស៊ុលក្នុងនិងក្រៅមណ្ឌលកុងស៊ុល នៅក្នុងរដ្ឋដទៃ ឬ ក្នុងនាមនៃរដ្ឋដទៃ ការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរនៃរដ្ឋជាម្ចាស់ផ្ទះ

១. យោងតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋជាម្ចាស់ផ្ទះ មន្ត្រីកុងស៊ុលមានសិទ្ធិបំពេញមុខងារកុងស៊ុល ក្នុងមណ្ឌលកុងស៊ុលដូចចែងក្នុងអនុសញ្ញានេះ ។

២. នៅក្នុងករណីពិសេស មន្ត្រីកុងស៊ុលអាចបំពេញមុខងារកុងស៊ុល នៅក្រៅមណ្ឌលកុងស៊ុលរបស់ខ្លួនបាន ដោយមានការយល់ព្រមពីរដ្ឋជាម្ចាស់ផ្ទះ ។

៣. ល្គឹកណាគ្មានការជំទាស់ជាក់លាក់ពីរដ្ឋសាមីនោះ រដ្ឋដាក់កុងស៊ុលអាចចាត់ប៉ុស្តិ៍កុងស៊ុលដែលបានបង្កើតក្នុងរដ្ឋម្ចាស់ផ្ទះ បំពេញមុខងារកុងស៊ុលនៅក្នុងរដ្ឋដទៃផ្សេងទៀត ក្រោយពីផ្តល់ដំណឹងដល់រដ្ឋសាមី ។

៤. ក្រោយពីបានជូនដំណឹងសមស្របដល់រដ្ឋម្ចាស់ផ្ទះ ប៉ុស្តិ៍កុងស៊ុលនៃរដ្ឋដាក់កុងស៊ុលអាចបំពេញមុខងារកុងស៊ុលជំនួសរដ្ឋដទៃទៀតក្នុងរដ្ឋម្ចាស់ផ្ទះ ប្រសិនបើរដ្ឋម្ចាស់ផ្ទះនេះ មិនជំទាស់ទេ ។

៥. ក្នុងការបំពេញមុខងាររបស់ខ្លួន មន្ត្រីប៉ុស្តិ៍កុងស៊ុលអាចធ្វើទំនាក់ទំនងជាមួយ :

ក/. អាជ្ញាធរមានសមត្ថកិច្ចមូលដ្ឋានក្នុងមណ្ឌលកុងស៊ុល

ខ/. អាជ្ញាធរមានសមត្ថកិច្ចកណ្តាលនៃរដ្ឋម្ចាស់ផ្ទះ ប្រសិនបើច្បាប់, បទបញ្ញត្តិ និងទំលាប់នៃរដ្ឋជាម្ចាស់ផ្ទះ ឬ កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនានាអនុញ្ញាតឱ្យធ្វើដូច្នេះ ។

## មាត្រា ៣៦

## មុខងារកុងស៊ុលជាទូទៅ

មុខងារកុងស៊ុលមានដូចតទៅ :

១. ការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់រដ្ឋដាក់កុងស៊ុល និង របស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ទាំងរូបវន្តបុគ្គលនិងនីតិបុគ្គលរបស់ខ្លួន នៅក្នុងរដ្ឋម្ចាស់ផ្ទះ ។

២. ជំរុញការអភិវឌ្ឍន៍ទំនាក់ទំនងពាណិជ្ជកម្ម, សេដ្ឋកិច្ច, វប្បធម៌ និង វិទ្យាសាស្ត្ររវាងរដ្ឋដាក់កុងស៊ុលនិងរដ្ឋម្ចាស់ផ្ទះ ក៏ដូចជាការពង្រឹងទំនាក់ទំនងមិត្តភាពរវាងរដ្ឋទាំងពីរ ដោយអនុលោមតាមបញ្ញត្តិនៃអនុសញ្ញានេះ ។

៣. ស្វែងយល់បន្ថែមទៀត ដោយប្រើគ្រប់មធ្យោបាយស្របច្បាប់ ពីស្ថានភាព និង ការរីកចំរើនក្នុងវិស័យពាណិជ្ជកម្ម, សេដ្ឋកិច្ច, វប្បធម៌ និង វិទ្យាសាស្ត្រ នៃរដ្ឋជាម្ចាស់ផ្ទះ និង ធ្វើរបាយការណ៍ជូនរដ្ឋាភិបាលនៃរដ្ឋដាក់កុងស៊ុល និង ផ្តល់ដំណឹងដល់សាមីបុគ្គលដែលពាក់ព័ន្ធ ។

៤. ផ្តល់ ពន្យាពេល កែតំរូវ បន្ថែម លុបចោល ដកហូត ឬ តំកល់ទុកលិខិតឆ្លងដែននិងលិខិតធ្វើដំណើរផ្សេងៗទៀត របស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល និង ផ្តល់ពន្យាពេល ឬ លុបចោលទិដ្ឋាការ ឬ លិខិតស្នាមសមស្របផ្សេងៗដល់ជនទាំងឡាយណា ដែលមានបំណងធ្វើដំណើរទៅកាន់រដ្ឋដាក់កុងស៊ុល ដោយអនុលោមតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋដាក់កុងស៊ុល ។

៥. ផ្តល់ការសង្គ្រោះនិងការឧបត្ថម្ភដល់នីតិបុគ្គលនិងពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ។

៦. បញ្ជាក់លើលិខិតស្នាម បំពេញនាទីជាសារការីនិងជាមន្ត្រីអត្រានុកូលដ្ឋាន និង បំពេញសមត្ថកិច្ចប្រហាក់ប្រហែលគ្នាដទៃទៀត ជូនពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល បំពេញមុខងាររដ្ឋបាលមួយចំនួនទៀត ដែលមិនប៉ះពាល់ដល់ច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ។

៧. បំពេញមុខងារផ្សេងៗពាក់ព័ន្ធដល់បញ្ហាសញ្ជាតិ និង ការចុះបញ្ជីអត្រានុកូលដ្ឋាន ដោយអនុលោមតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋដាក់កុងស៊ុល ។

៨. ការពារផលប្រយោជន៍របស់នីតិបុគ្គលនិងពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ក្នុងករណីដែលមានការស្នងមរតកក្រោយមរណៈភាពក្នុងទឹកដីនៃរដ្ឋជាម្ចាស់ផ្ទះ ដោយអនុលោមតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ។

៩. ការពារផលប្រយោជន៍របស់អនីតិជន និង អសមត្ថជនផ្សេងៗទៀតដែលជាពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ជាពិសេសក្នុងករណីតំរូវឱ្យមានអាណាព្យាបាល ឬ អ្នកគាំពារសំរាប់ជនទាំងនោះ ក្នុងកំរិតដែលច្បាប់និងបទបញ្ញត្តិរបស់រដ្ឋជាម្ចាស់ផ្ទះកំណត់ឱ្យ ។

១០. ស្របតាមការអនុវត្តន៍និងនីតិវិធីជាធរមាននៅក្នុងរដ្ឋម្ចាស់ផ្ទះ តំណាងឱ្យ ឬ ចាត់ឱ្យមានអ្នកតំណាងសមស្របសំរាប់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ស្របតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីស្នើសុំឱ្យចាត់វិធានការណ៍បណ្តោះអាសន្ន សំដៅថែរក្សាគាំពារសិទ្ធិនិងផលប្រយោជន៍នៃពលរដ្ឋទាំងនោះ ដែលដោយមូលហេតុអវត្តមាន ឬ ដោយមូលហេតុផ្សេងទៀត ពលរដ្ឋទាំងនោះ មិនអាចមានលទ្ធភាពការពារសិទ្ធិនិងផលប្រយោជន៍របស់គេទាន់ពេលវេលា ។

១១. បញ្ជូនសំណុំឯកសារតុលាការនិងឯកសារក្រៅកិច្ចការតុលាការ ឬ អនុវត្តការប្រគល់ភារកិច្ចស៊ើបអង្កេតជូនតុលាការរដ្ឋដាក់កុងស៊ុល យោងតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានជាធរមាន ឬ ប្រសិនបើគ្មានកិច្ចព្រមព្រៀងអន្តរជាតិទាំងនោះទេ ត្រូវធ្វើតាមនីតិវិធីផ្សេងទៀតដែលសមស្របតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ។

១២. ប្រើសិទ្ធិត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ច ដូចចែងក្នុងច្បាប់និងបទបញ្ញត្តិនៃរដ្ឋដាក់កុងស៊ុលទៅលើជលយានដែលបង្កួតទង់ជាតិនៃរដ្ឋដាក់កុងស៊ុល និង យន្តហោះដែលចុះបញ្ជីក្នុងរដ្ឋនោះ ព្រមទាំងក្រុមយានិករបស់យានទាំងនោះផង ។

១៣. ផ្តល់ការជួយសង្គ្រោះដល់ជលយាន និង យន្តហោះ ដូចរៀបរាប់ក្នុងកថាខ័ណ្ឌទី១២នៃមាត្រានេះ និង យានិករបស់យានទាំងនោះ ទទួលរបាយការណ៍ពីការធ្វើដំណើររបស់ជលយានណាមួយ ពិនិត្យនិងបោះត្រាលើសំណុំឯកសារនាវា និង ដោយមិនធ្វើឱ្យប៉ះពាល់សិទ្ធិអំណាចនៃអាជ្ញាធរ របស់រដ្ឋជាម្ចាស់ផ្ទះ, ធ្វើការស៊ើបអង្កេតអំពីឧប្បត្តិហេតុណាមួយ ដែលកើតឡើងក្នុងពេលធ្វើដំណើរ និង ដោះស្រាយរាល់វិវាទផ្សេងៗរវាងនាវាបតី សេនាបតី និង នាវិក តាមកំរិតណាមួយ ដែលច្បាប់និងបទបញ្ញត្តិនៃរដ្ឋដាក់កុងស៊ុល អនុញ្ញាតឱ្យធ្វើ ។

១៤. បំពេញនូវមុខងារផ្សេងៗទៀត ដែលរដ្ឋដាក់កុងស៊ុលបានប្រគល់ជូនប៉ុស្តិ៍កុងស៊ុលដែលច្បាប់និងបទបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះមិនហាមឃាត់ ឬ មិនជំទាស់ ឬ ដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិជាធរមាន រវាងរដ្ឋដាក់កុងស៊ុលនិងរដ្ឋម្ចាស់ផ្ទះ ។

## មាត្រា ៣៧

## ការប្រាស្រ័យទាក់ទងជាមួយពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល

មន្ត្រីកុងស៊ុលអាចធ្វើការប្រាស្រ័យទាក់ទង និង ទាក់ទងដោយផ្ទាល់ជាមួយពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលដោយសេរី ។ ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលក៏មានសេរីភាពដូចគ្នា ក្នុងការទាក់ទងជាមួយ ឬ ចូលជួបប្រាស្រ័យជាមួយមន្ត្រីប៉ុស្តិ៍កុងស៊ុលនៃរដ្ឋដាក់កុងស៊ុល ។

## មាត្រា ៣៨

## មុខងារកុងស៊ុល ស្តីពីការឃុំខ្លួននិងការជំនុំជំរះក្តី

១. ប្រសិនបើពលរដ្ឋម្នាក់នៃរដ្ឋដាក់កុងស៊ុល ដែលត្រូវបានជាប់ឃុំក្នុងមណ្ឌលកុងស៊ុល

បានស្នើសុំអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវបញ្ជូនដំណឹងដោយមិនបង្អែរបង្អង់ ដល់ប៉ុស្តិ៍កុងស៊ុលនៃរដ្ឋដាក់កុងស៊ុល ។

២. អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះត្រូវបញ្ជូនដោយមិនបង្អង់ទៅប៉ុស្តិ៍កុងស៊ុល នូវរាល់ការឆ្លើយឆ្លង ឬទំនាក់ទំនង ដែលពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលជាប់ឃុំ ផ្ញើជូនប៉ុស្តិ៍កុងស៊ុលរបស់គេ ។

៣. មន្ត្រីប៉ុស្តិ៍កុងស៊ុលត្រូវមានសិទ្ធិសាកសួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយពលរដ្ឋជាប់ឃុំនៃរដ្ឋដាក់កុងស៊ុល និង ត្រូវចាត់ចែងឱ្យមានអ្នកតំណាងការពារស្របច្បាប់របស់គេ ។

៤. មន្ត្រីកុងស៊ុលត្រូវជៀសវាងមិនធ្វើសកម្មភាពអ្វីទាំងអស់ ក្នុងផលប្រយោជន៍ពលរដ្ឋជាប់ឃុំនៃរដ្ឋដាក់កុងស៊ុល ប្រសិនបើពលរដ្ឋនោះជំទាស់យ៉ាងដាច់ខាតចំពោះសកម្មភាពនេះ ។

៥. ពលរដ្ឋជាប់ឃុំនឹងត្រូវមានសិទ្ធិទទួលនិងផ្ញើលិខិត និង ការឆ្លើយឆ្លងឯទៀត និងទទួលកញ្ចប់ឥវ៉ាន់សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ក្នុងកំរិតដែលច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ កំណត់ឱ្យ ។

៦. ក្នុងករណីមានការជំនុំជំរះក្តី ឬ មាននីតិវិធីផ្សេងៗទៀតទៅលើពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល នៅក្នុងរដ្ឋម្ចាស់ផ្ទះ, អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវផ្តល់ទៅមន្ត្រីប៉ុស្តិ៍កុងស៊ុលនៃរដ្ឋដាក់កុងស៊ុល ដំណឹងតាមសំណើនៃជនខាងលើនេះ ស្តីពីការចោទប្រកាន់ទៅលើជនរូបនោះ ព្រមទាំងពេលវេលា, កាលបរិច្ឆេទ និង ទីកន្លែងនៃការជំនុំជំរះក្តី ឬ នីតិវិធីផ្សេងទៀត ។ មន្ត្រីប៉ុស្តិ៍កុងស៊ុលនឹងមានសិទ្ធិចូលរួមក្នុងការជំនុំជំរះក្តី ឬ ក្នុងនីតិវិធីក្តីផ្សេងៗទៀត ទៅលើជននោះ ។

៧. អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវផ្តល់ដំណឹងដល់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ដែលត្រូវជាប់ឃុំ ឬ ត្រូវជំនុំជំរះ ឬ ទទួលនីតិវិធីផ្សេងទៀត យោងតាមបញ្ញត្តិនៃមាត្រានេះ ។

៨. បញ្ញត្តិនៃមាត្រានេះនិងមាត្រាទី៣៧ ត្រូវអនុវត្តផងដែរ ចំពោះពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ដែលត្រូវបានជាប់ឃុំ, ចាប់ខ្លួន ឬ ស្ថិតក្រោមការកំរិតសេរីភាពផ្ទាល់ខ្លួនតាមរូបភាពណាមួយផ្សេងទៀត រួមទាំងជនទាំងឡាយណា ដែលកំពុងជាប់ពន្ធនាគារក្នុងរដ្ឋជាម្ចាស់ផ្ទះ ។

៩. បណ្តាសិទ្ធិដូចមានចែងក្នុងមាត្រានេះ នឹងត្រូវបានប្រើប្រាស់ស្របតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ដរាបណាច្បាប់និងបទបញ្ញត្តិទាំងនោះ ត្រូវតែសំរួលដល់ការសំរេចបានទិសដៅពេញលេញ ដែលជាមូលហេតុឱ្យកើតមានសិទ្ធិទាំងនោះ ។

## មាត្រា ៣៩

## មុខងារពាក់ព័ន្ធដល់ការស្លាប់មរណភាព

១. ក្នុងករណីមរណៈភាពនៃពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវផ្តល់ដំណឹងជាបន្ទាន់ នៅពេលដែលបានទទួលដំណឹងជាបន្ទាន់ពីមរណៈភាពនោះ ទៅប៉ុស្តិ៍កុងស៊ុលនៃមណ្ឌលដែលមរណៈភាពនេះកើតឡើង និង ចេញនូវសំបុត្រមរណៈភាព ឬ សេចក្តីចំលងឯកសារផ្សេងទៀត ដែលទាក់ទងទៅនឹងមរណៈភាពនេះ ដោយឥតគិតថ្លៃ ។

២. នៅពេលដែលបានទទួលដំណឹងពីមរណៈភាព នៃពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវផ្តល់ដំណឹងឱ្យទាន់ពេលវេលាទៅមន្ត្រីកុងស៊ុល នៃរដ្ឋដាក់កុងស៊ុល អំពី :

ក/. ការផ្តួចផ្តើមឱ្យមានការគ្រប់គ្រងនូវមរតក ដែលបណ្តាលពីមរណៈភាពនៃពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល ហើយពលរដ្ឋនោះពុំទាន់បានចាត់តាំងនរណាម្នាក់នៃរដ្ឋម្ចាស់ផ្ទះ ដើម្បីឱ្យគ្រប់គ្រង ឬ រក្សាមរតកទាំងនោះ ឬ តំណាងឱ្យខ្លួន ឬ

ខ/. ការផ្តួចផ្តើមឱ្យមាននីតិវិធីផ្ទេរមរតករបស់ជនណាម្នាក់ ទោះបីមានសញ្ជាតិអ្វីក៏ដោយ ដែលបានបន្សល់ទុកក្នុងរដ្ឋម្ចាស់ផ្ទះនូវមរតកមួយ ដែលពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ដែលពុំមានទីលំនៅអចិន្ត្រៃយ៍នៃរដ្ឋម្ចាស់ផ្ទះ ហើយពុំមានអ្នកតំណាងនៅទីនោះ អាចទទួលផលតាមបណ្តាំមរតក ឬ បើពុំនោះ ដោយអនុលោមតាមច្បាប់ឬបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ។

៣. ចំពោះបញ្ហាមរតកដូចមានកំណត់ក្នុងកថាខ័ណ្ឌ២នៃមាត្រានេះ នឹងស្របតាមច្បាប់ និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ មន្ត្រីកុងស៊ុលម្នាក់មានសិទ្ធិ :

ក/. ស្នើដល់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ឱ្យចាត់វិធានការចាំបាច់នានា ដើម្បីការពារការថែរក្សានិងការគ្រប់គ្រងនូវមរតក ។

ខ/. មានវត្តមាន ឬ បើពុំនោះចូលរួមក្នុងការចាត់វិធានការទាំងឡាយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ(ក) នៃកថាខ័ណ្ឌ៣ របស់មាត្រានេះ ។

គ/. ចាត់ចែងឱ្យមានតំណាងនៃពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល ដែលមានផលប្រយោជន៍ស្របច្បាប់ទៅលើមរតកនោះ ដែលអវត្តមាននិងគ្មានអ្នកតំណាងក្នុងរដ្ឋម្ចាស់ផ្ទះ ។

៤. ប្រសិនបើពលរដ្ឋម្នាក់នៃរដ្ឋដាក់កុងស៊ុល ដែលពុំមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ ស្លាប់ក្នុងរយៈពេលស្នាក់នៅបណ្តោះអាសន្ន ឬ ឆ្លងកាត់រដ្ឋម្ចាស់ផ្ទះ មន្ត្រីកុងស៊ុលអាចប្រមូលទ្រព្យសម្បត្តិទាំងនោះមកកាន់កាប់ជាបន្ទាន់ ដើម្បីការពារនិងថែរក្សានូវប្រាក់កាស និង ទ្រព្យសម្បត្តិនៃសព ដោយមានការសំរុះសំរួលសមស្រប ជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅទីកន្លែង ។ ស្របតាមច្បាប់និងបទបញ្ញត្តិស្តីពីការស្នងមរតកនៃរដ្ឋម្ចាស់ផ្ទះ និង រដ្ឋដាក់កុងស៊ុល មន្ត្រីកុងស៊ុលត្រូវមានសិទ្ធិទទួល និង ការពារនូវវត្ថុទាំងឡាយ ដែលសពមានជាប់នឹងខ្លួនសំរាប់ប្រើប្រាស់ផ្ទាល់ ។

៥. រដ្ឋជាក់កុងស៊ុលនិងរដ្ឋម្ចាស់ផ្ទះ នឹងសម្រួលនូវការផ្ទេរមរតក :

ក/. ដោយយល់ព្រមឱ្យនាំចូលនិងនាំចេញនូវវត្ថុទាំងឡាយដែលជាមរតក ដរាបណាការនាំចេញនិងនាំចូលវត្ថុទាំងនោះ មិនត្រូវបានហាមឃាត់ដោយជាក់លាក់ដោយច្បាប់និងបទបញ្ញត្តិរបស់រដ្ឋ ដែលតម្រូវឱ្យមានការយល់ព្រមក្នុងការនាំចេញនិងនាំចូល ។

ខ/. ដោយអនុញ្ញាតឱ្យលក់នូវផ្នែកណាមួយនៃមរតក ដែលត្រូវបានហាមឃាត់មិនឱ្យនាំចេញ ស្របតាមបញ្ញត្តិនៃវាក្យខ័ណ្ឌ(ក) នៃកថាខ័ណ្ឌ៥ របស់មាត្រានេះ ។

គ/. ដោយអនុញ្ញាតឱ្យផ្ទេរប្រាក់បានពីការលក់ខាងលើនេះ បន្ទាប់ពីបានដកសោហ៊ុយពន្ធនិងអាករ ទៅឱ្យអ្នកទទួលមរតកក្នុងរដ្ឋដែលគេរស់នៅ ជារូបិយប័ណ្ណដែលមានតំលៃដោះដូរបាន ។ ការផ្ទេរប្រាក់ត្រូវធ្វើឡើងស្របតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋ ដែលមរតកស្ថិតនៅ ។

## មាត្រា ៤០
## តួនាទីស្តីពីអត្រានុកូលដ្ឋាន

១. មន្ត្រីកុងស៊ុលមានសិទ្ធិ :

ក/. កាន់បញ្ជីកំណើតនិងមរណៈភាពរបស់ពលរដ្ឋនៃរដ្ឋជាក់កុងស៊ុល ទទួលនិងស្នើអាជ្ញាធរមានសមត្ថកិច្ច ឱ្យផ្តល់ដំណឹងផ្សេងៗនិងឯកសារនានាពាក់ព័ន្ធពីបញ្ហាទាំងនោះ ។

ខ/. ទទួលពាក្យសុំ ឬ ការប្រកាស ដែលពាក់ព័ន្ធដល់អត្រានុកូលដ្ឋានរបស់ពលរដ្ឋនៃរដ្ឋជាក់កុងស៊ុល ។

គ/. ចុះអាពាហ៍ពិពាហ៍រវាងពលរដ្ឋនៃរដ្ឋជាក់កុងស៊ុល ។

ឃ/. ចុះអាពាហ៍ពិពាហ៍រវាងពលរដ្ឋនៃរដ្ឋជាក់កុងស៊ុល និង ពលរដ្ឋនៃរដ្ឋផ្សេងៗទៀត ស្របតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋជាក់កុងស៊ុល និង រដ្ឋម្ចាស់ផ្ទះ ។

ង/. ចុះបញ្ជីពីការសុំកូនចិញ្ចឹម ស្របតាមច្បាប់និងបទបញ្ញត្តិនៃរដ្ឋជាក់កុងស៊ុល ។

២. ក៏ប៉ុន្តែបញ្ញត្តិដូចមានចែងក្នុងកថាខ័ណ្ឌទី១នៃមាត្រានេះ មិនលើកលែងឱ្យសាមីជនរួចផុតពីកាតព្វកិច្ចត្រូវគោរពច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះឡើយ ។

៣. អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ មានកាតព្វកិច្ចផ្តល់ពត៌មានជាបន្ទាន់ទៅមន្ត្រីកុងស៊ុល អំពីករណីចាំបាច់ត្រូវចាត់តាំងអាណាព្យាបាល ឬ អ្នកការពារ ដើម្បីការពារផលប្រយោជន៍អនីតិជន ឬ អសមត្ថជនដែលជាពលរដ្ឋនៃរដ្ឋជាក់កុងស៊ុល នៅពេលអាជ្ញាធរទាំងនោះបានទទួលពត៌មានពីបញ្ហានេះ ។ ការផ្តល់ពត៌មាននេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់ច្បាប់និងច្បាប់សញ្ញាតិជា

ធរមាននៃរដ្ឋម្ចាស់ផ្ទះ ស្តីពីការតែងតាំងខាងលើនេះ ។

## មាត្រា ៩១
## មុខងារជាសារការី និង និត្យានុកូលកម្ម

មន្ត្រីកុងស៊ុលនឹងត្រូវមានសិទ្ធិ :

១. បញ្ជាក់កិច្ចសន្យា ប្រសិនបើកិច្ចសន្យាទាំងអស់នេះ ត្រូវយកមកអនុវត្តនៅក្នុងរដ្ឋដាក់កុងស៊ុល ឬ ដោយពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល លើកលែងតែការផ្ទេរកម្មសិទ្ធិអចលនវត្ថុនៅក្នុងរដ្ឋម្ចាស់ផ្ទះ រវាងពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលគ្នាឯង ឬ រវាងពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលនិងពលរដ្ឋនៃប្រទេសផ្សេងទៀត ។

២. បញ្ជាក់លើបណ្តាំមរតករបស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល និង ការពារមរតកសាសនីនោះ ប្រសិនបើមានសំណូមពរឱ្យធ្វើ ។

៣. បញ្ជាក់លើការប្រគល់សិទ្ធិធ្វើដោយនីតិបុគ្គល និង ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល បញ្ជាក់ថាស្របច្បាប់លើឯកសារ សក្ខីប័ណ្ណ ការបកប្រែ ការថតចំលង ហត្ថលេខា កាលបរិច្ឆេទក្នុងឯកសារ និង សក្ខីប័ណ្ណ ។

៤. បញ្ជាក់ថាស្របច្បាប់លើឯកសារ និង សក្ខីប័ណ្ណដែលធ្វើឡើង ស្របតាមច្បាប់និងបទបញ្ញត្តិជាធរមានរបស់រដ្ឋនិមួយៗ ដោយអាជ្ញាធរនៃរដ្ឋដាក់កុងស៊ុល និង រដ្ឋម្ចាស់ផ្ទះ ។

ឯកសារនិងសក្ខីប័ណ្ណ ដូចបានរៀបរាប់ក្នុងមាត្រានេះ ដែលធ្វើឡើងបញ្ជាក់ ឬ បញ្ជាក់ថាស្របច្បាប់ដោយមន្ត្រីកុងស៊ុល នឹងត្រូវបានចាត់ទុកថាមានតំលៃដូចគ្នាទៅនឹងឯកសារនិងសក្ខីប័ណ្ណធ្វើឡើង ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ប្រសិនបើវាមិនផ្ទុយនឹងច្បាប់និងបទបញ្ញត្តិរបស់រដ្ឋនោះ ។

## មាត្រា ៩២
## ការរក្សាការពារ ឯកសារ និង វត្ថុមានតំលៃ

១. តាមសំណូមពររបស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល និង ប្រសិនបើវាមិនផ្ទុយនឹងច្បាប់ ឬ បទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ មន្ត្រីកុងស៊ុលអាចទទួលទុកនូវឯកសារ ឬ វត្ថុមានតំលៃ ដើម្បីរក្សាការពារ ។

២. មន្ត្រីកុងស៊ុលមានសិទ្ធិទទួលផងដែរ នូវវត្ថុដែលបាត់បង់របស់ពលរដ្ឋនៃរដ្ឋដាក់

កុងស៊ុល ក្នុងរយៈពេលស្នាក់នៅក្នុងរដ្ឋម្ចាស់ផ្ទះ ដើម្បីប្រគល់ឱ្យម្ចាស់ដើមវិញ ។

## មាត្រា ៤៣

## ការផ្តល់កិច្ចឧបត្ថម្ភដល់នាវានៃរដ្ឋដាក់កុងស៊ុល

១. មន្ត្រីកុងស៊ុលមានសិទ្ធិផ្តល់កិច្ចឧបត្ថម្ភ និង ការគាំទ្រសមស្របដល់នាវានៃរដ្ឋដាក់កុងស៊ុល ក្នុងរយៈពេលសំចតនៅកំពង់ផែ ឬ កន្លែងបោះយុថ្ការបស់រដ្ឋម្ចាស់ផ្ទះ ឬ នៅក្នុងដែនសមុទ្រនិងដែនទឹកផ្ទៃក្នុង ឬ ដងទន្លេនៃរដ្ឋម្ចាស់ផ្ទះ ល្គឹកណាដែលតំបន់ទឹកទាំងនេះ ស្ថិតនៅក្នុងមណ្ឌលកុងស៊ុល ។

២. នាវាបតី និង សមាជិកក្រុមនាវិកមានសិទ្ធិជួបនិងទាក់ទងជាមួយនឹងមន្ត្រីកុងស៊ុលលើនាវា ឬ កន្លែងណាផ្សេងទៀត ដែលស្ថិតក្នុងមណ្ឌលកុងស៊ុលនិងទៅទាក់ទងដល់ប៉ុស្តិ៍កុងស៊ុលស្របទៅតាមច្បាប់និងច្បាប់បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ជាពិសេសច្បាប់បញ្ញត្តិស្តីពីកំពង់ផែ និង ច្បាប់និងច្បាប់បញ្ញត្តិស្តីពីការឆ្លងដែន ។

៣. មន្ត្រីកុងស៊ុលអាចទាក់ទងជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ និង ស្នើសុំការគាំទ្រក្នុងការបំពេញមុខងាររបស់ខ្លួន លើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជលយាន នាវាបតី សមាជិកក្រុមនាវិក និង ទំនិញលើនាវា ។

## មាត្រា ៤៤

## ការផ្តល់កិច្ចឧបត្ថម្ភដល់នាវាបតី និង ក្រុមនាវិក

១. ដរាបណាដែលសកម្មភាពខាងក្រោមនេះ មិនផ្ទុយនឹងច្បាប់និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ មន្ត្រីកុងស៊ុលមានសិទ្ធិ :

ក/. ស្រាវជ្រាវអំពីឧប្បត្តិហេតុណាមួយ ដែលកើតឡើងលើនាវា នៃរដ្ឋដាក់កុងស៊ុល, សាកសួរនាវាបតីនិងសមាជិកណាម្នាក់នៃក្រុមនាវិក អំពីឧប្បត្តិហេតុទាំងឡាយនេះ ត្រួតពិនិត្យលិខិតស្នាមរបស់នាវា ទទួលពត៌មានដែលពាក់ព័ន្ធដល់ការធ្វើដំណើរ និង គោលដៅរបស់នាវា ព្រមទាំងផ្តល់កិច្ចឧបត្ថម្ភ ចំពោះការចូលចតនិងការចេញដំណើរនៃនាវា និង ការសំចតនៅកំពង់ផែ ។

ខ/. ដោះស្រាយវិវាទរវាងអ្នកនាវាបតីនិងសមាជិកក្រុមនាវិក រួមទាំងវិវាទស្តីពីប្រាក់បៀវត្ស និង កិច្ចសន្យាការងារ ។

គ/. ចាត់វិធានការពាក់ព័ន្ធដល់ការជ្រើសរើស ឬ ផ្លាស់ប្តូរនាវាបតីនិងសមាជិកក្រុមនាវិកទាំងអស់ ។

ឃ/. សំរួលការព្យាបាលជំងឺដល់នាវាបតី សមាជិកក្រុមនាវិក ឬ អ្នកដំណើរនៃនាវា និង សំរួលការធ្វើមាតុភូមិនិវត្តន៍ ទៅកាន់រដ្ឋដាក់កុងស៊ុលវិញ ។

ង/. ទទួល, តាក់តែង, បញ្ជាក់ ឬ ពន្យាពេល រាល់សេចក្តីប្រកាសណាមួយ ឬ រាល់ឯកសារផ្សេងៗ ស្របទៅនឹងច្បាប់ឬបទបញ្ញាត្តិនៃរដ្ឋដាក់កុងស៊ុល ស្តីអំពីនាវានៃរដ្ឋដាក់កុងស៊ុល ឬ ទំនិញលើនាវា ។

ច/. ចាត់វិធានការផ្សេងៗទៀត ដូចបានចែងក្នុងច្បាប់និងបទបញ្ញាត្តិនៃរដ្ឋដាក់កុងស៊ុល ស្តីអំពីការដឹកជញ្ជូនពាណិជ្ជកម្មតាមនាវា ។

២. មន្ត្រីកុងស៊ុលមានសិទ្ធិបង្ហាញខ្លួនរួមជាមួយនាវាបតី ឬ សមាជិកក្រុមនាវិកណាម្នាក់ចំពោះមុខតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីផ្តល់កិច្ចឧបត្ថម្ភដល់អ្នកទាំងនោះ ស្របទៅនឹងច្បាប់និងបទបញ្ញាត្តិនៃរដ្ឋម្ចាស់ផ្ទះ ។

## មាត្រា ៤៥

## ការការពារផលប្រយោជន៍ ក្នុងករណីមានវិធានការបង្ខិតបង្ខំផ្សេងៗលើនាវា

១. ប្រសិនបើតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតនៃរដ្ឋម្ចាស់ផ្ទះ មានបំណងអនុវត្តវិធានការបង្ខិតបង្ខំ ឬ ធ្វើការស៊ើបអង្កេតលើនាវានៃរដ្ឋដាក់កុងស៊ុល ដែលស្ថិតក្នុងដែនទឹកផ្ទៃក្នុង ដែនសមុទ្រ ឬ ដងទន្លេនៃរដ្ឋម្ចាស់ផ្ទះដែលស្ថិតនៅក្នុងមណ្ឌលកុងស៊ុល មន្ត្រីកុងស៊ុលនឹងត្រូវទទួលពត៌មានជាមុន ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអាចមានវត្តមាននៅពេលដែលគេអនុវត្តវិធានការទាំងនោះ ។ ប្រសិនបើមន្ត្រីកុងស៊ុលអវត្តមាន នៅពេលដែលគេចាប់ផ្តើមអនុវត្តវិធានការនោះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ផ្តល់ពត៌មានជាលាយល័ក្ខអក្សរទៅមន្ត្រីកុងស៊ុល ស្តីពីការអនុវត្តន៍វិធានការខាងលើ តាមការស្នើសុំ ។ ក្នុងគ្រប់ករណី ប្រសិនបើភាពបន្ទាន់នៃវិធានការដែលត្រូវចាត់ឡើងនោះ មិនអាចអនុញ្ញាតឱ្យមានការផ្តល់ពត៌មានជាមុន ទៅមន្ត្រីកុងស៊ុលបាន អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ នឹងត្រូវផ្តល់ពត៌មានទៅមន្ត្រីកុងស៊ុលជាលាយល័ក្ខអក្សរ ពីហេតុការណ៍និងវិធានការដែលត្រូវបានចាត់ឡើង ។

២. បញ្ញាត្តិទាំងឡាយក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ នឹងអនុវត្តផងដែរ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ កោះហៅនាវាបតី ឬ សមាជិកក្រុមនាវិកនៃនាវាណាមួយនៃ

រដ្ឋជាក់កុងស៊ុល ឱ្យឡើងលើគោក ដើម្បីឆ្លើយនឹងសំណួរទាំងឡាយ ស្តីពីបញ្ហានាវា ។

៣. លើកលែងតែមានសំណូមពរ ឬ ការអនុញ្ញាតិរបស់មន្ត្រីកុងស៊ុល ឬ នាវាបតីនៃនាវានៃរដ្ឋជាក់កុងស៊ុល តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតនៃរដ្ឋម្ចាស់ផ្ទះ នឹងមិនជ្រៀតជ្រែកទៅលើនាវានៃរដ្ឋជាក់កុងស៊ុល ចូលក្នុងបញ្ហាដែលជាទំនាក់ទំនងរវាងសមាជិកនៃក្រុមនាវិក ទំនាក់ទំនងពលកម្ម វិន័យទៅលើនាវា និង សកម្មភាពផ្សេងៗទៀត ដែលមានលក្ខណៈផ្ទៃក្នុងនៃនាវា លើកណាច្បាប់និងបទបញ្ញត្តិស្តីពីសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាព នៃរដ្ឋម្ចាស់ផ្ទះមិនត្រូវបានរំលោភ ។

៤. បញ្ញត្តិទាំងឡាយនៃមាត្រានេះ នឹងមិនអនុវត្តចំពោះការត្រួតពិនិត្យជាធម្មតា ផ្នែកគយ អន្តោប្រវេសន៍ លិខិតឆ្លងដែន និង ការត្រួតពិនិត្យសុខភាពសាធារណៈ អនាម័យ និង ចត្តាឡីស័ក្ត ព្រមទាំងវិធានការចាំបាច់ឯទៀតដែលត្រូវចាត់ ដើម្បីរក្សានិងស្តារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងរដ្ឋម្ចាស់ផ្ទះ ។ បញ្ញត្តិនៃមាត្រានេះ នឹងមិនអនុវត្តចំពោះវិធានការទាំងឡាយដែលត្រូវប្រកាន់យក ក្នុងការអនុវត្តនីបញ្ញត្តិនៃសន្ធិសញ្ញាពហុភាគីជាធរមាន ដែលប្រទេសទាំងពីរជាភាគីក្នុងនោះ ដើម្បីសង្គ្រោះអាយុជីវិតមនុស្សក្នុងសមុទ្រ និង ការទប់ស្កាត់ភាពក្រខ្វក់នៃបរិស្ថានសមុទ្រ ។

## មាត្រា ៤៦

## កិច្ចឧបត្ថម្ភក្នុងករណីមានគ្រោះថ្នាក់ដល់នាវា

១. ប្រសិនបើនាវានៃរដ្ឋជាក់កុងស៊ុលត្រូវផ្ទុះធ្លាយ ឬ កៀង ឬ ទទួលរងការខូចខាតណាមួយផ្សេងទៀតក្នុងដែនសមុទ្រ ឬ ដែនទឹកផ្ទៃក្នុងនៃរដ្ឋម្ចាស់ផ្ទះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះនឹង ផ្តល់ដំណឹងទៅមន្ត្រីកុងស៊ុលក្នុងកាលដ៏គួរបំផុត អំពីវិធានការដែលបានចាត់ ដើម្បីជួយសង្គ្រោះអ្នកដំណើរ និង សមាជិកក្រុមនាវិក ព្រមទាំងសង្គ្រោះនាវានិងទំនិញ ។

២. មន្ត្រីកុងស៊ុលត្រូវជួយនាវានៃរដ្ឋជាក់កុងស៊ុល សមាជិកក្រុមនាវិក អ្នកដំណើរនៃនាវាដែលជាពលរដ្ឋរបស់រដ្ឋជាក់កុងស៊ុល ។ មន្ត្រីកុងស៊ុលអាចស្នើសុំផងដែរទៅរដ្ឋម្ចាស់ផ្ទះ ឱ្យផ្តល់កិច្ចឧបត្ថម្ភដូចគ្នានេះ ។

៣. ប្រសិនបើម្ចាស់នាវានៃរដ្ឋជាក់កុងស៊ុល នាវាបតី ឬ ជនដែលទទួលការអនុញ្ញាតិផ្សេងទៀតពុំមានលទ្ធភាពចាត់វិធានការចាំបាច់ ដើម្បីជួយការពារ សង្គ្រោះ ឬ ចាត់ចែងទ្រព្យសម្បត្តិលើនាវានិងទំនិញ មន្ត្រីកុងស៊ុលនៃរដ្ឋជាក់កុងស៊ុល តាងនាមឱ្យម្ចាស់នាវាអាចនឹងចាត់វិធានការទាំងនោះ ដែលម្ចាស់នាវា ឬ ម្ចាស់ទំនិញគួរតែចាត់ចែងក្នុងករណីបែបនេះ ឬ អាចស្នើសុំ

ទៅអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ឱ្យចាត់នូវវិធានការទាំងនោះ ។

៤. បញ្ញត្តិនៃកថាខ័ណ្ឌទី១, ២, ៣ នៃមាត្រានេះ នឹងត្រូវអនុវត្តផងដែរ ចំពោះសំភារៈដែលជាកម្មសិទ្ធិរបស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលដែលនៅលើនាវា ទោះនាវានោះជារបស់រដ្ឋដាក់កុងស៊ុល ឬ ជារបស់រដ្ឋដទៃ ដែលបានត្រូវរកឃើញនៅតាមឆ្នេរសមុទ្រ ឬ ក្នុងទឹកនៃរដ្ឋម្ចាស់ផ្ទះ ឬ ដែលបាននាំមកទុកនៅកំពង់ផែនៃរដ្ឋម្ចាស់ផ្ទះ ។

៥. អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ នឹងផ្តល់រាល់កិច្ចឧបត្ថម្ភចាំបាច់ដល់មន្ត្រីកុងស៊ុល ក្នុងការចាត់វិធានការទាំងឡាយ ដើម្បីជួយសង្គ្រោះនាវានៃរដ្ឋដាក់កុងស៊ុល ។

## មាត្រា ៤៧

## មុខងារដែលទាក់ទងនៅនឹងអាកាសយាន

មាត្រា៤៣, ៤៤, ៤៥ និង ៤៦ នៃអនុសញ្ញានេះ នឹងអនុវត្តដោយឥតខុសឆ្គងចំពោះអាកាសចរស៊ីវិលនៃរដ្ឋដាក់កុងស៊ុល ល្គឹកណាការអនុវត្តនីនោះ មិនផ្ទុយនឹងបញ្ញត្តិទាំងឡាយនៃអនុសញ្ញាទ្វេភាគី ឬ ពហុភាគី ដែលភាគីចុះកិច្ចសន្យាបានចុះហត្ថលេខា ឬ បានចូលរួម ។

## មាត្រា ៤៨

## ពន្ធនិងអាករកុងស៊ុល

១. ស្របទៅនឹងច្បាប់និងបទបញ្ញត្តិនៃរដ្ឋដាក់កុងស៊ុល ប៉ុស្តិ៍កុងស៊ុលមានសិទ្ធិហូតពន្ធនិងអាករ លើលិខិតស្នាមកុងស៊ុល នៅក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះ ។

២. ចំនួនទឹកប្រាក់ប្រមូលបានពីការហូតពន្ធនិងអាករ ដូចមានចែងក្នុងកថាខ័ណ្ឌទី១នៃមាត្រានេះ និង បង្កាន់ដៃពន្ធនិងអាករនេះ នឹងត្រូវបានរួចផុតពីពន្ធនិងអាករនៅក្នុងរដ្ឋម្ចាស់ផ្ទះ ។

៣. រដ្ឋម្ចាស់ផ្ទះនឹងអនុញ្ញាតិឱ្យប៉ុស្តិ៍កុងស៊ុលបញ្ចូលប្រាក់ប្រមូលបានពីពន្ធនិងអាករនោះទៅក្នុងគណនីធនាគារជាផ្លូវការរបស់ប៉ុស្តិ៍កុងស៊ុល ។

## ជំពូក V

## អវសានបញ្ញត្តិ

## មាត្រា ៤៩
## ការបញ្ចប់មុខងារ នៃសមាជិកប៉ុស្តិ៍កងស៊ីវិល

មុខងាររបស់សមាជិកនៃប៉ុស្តិ៍កុងស៊ុលនឹងត្រូវបញ្ចប់ជាអាទិ៍ដោយ :

ក/. ការជូនដំណឹងពីរដ្ឋដាក់កុងស៊ុលទៅរដ្ឋម្ចាស់ផ្ទះថា មុខងាររបស់ជននោះត្រូវបានបញ្ចប់ហើយ ។

ខ/. ការដកហូតនិកាសទាន ។

គ/. ការជូនដំណឹងពីរដ្ឋម្ចាស់ផ្ទះទៅរដ្ឋដាក់កុងស៊ុលថា រដ្ឋម្ចាស់ផ្ទះបានឈប់ទទួលស្គាល់ជននោះ ជាសមាជិកនៃបុគ្គលិកកុងស៊ុលហើយ ។

## មាត្រា ៥០
## ការចាកចេញពីដែនដីនៃរដ្ឋម្ចាស់ផ្ទះ

ទោះជាក្នុងករណីមានវិវាទដោយអាវុធក្តី រដ្ឋម្ចាស់ផ្ទះនឹងផ្តល់ជូនសមាជិកនៃប៉ុស្តិ៍កុងស៊ុល និងសមាជិកបុគ្គលិកឯកជនផ្សេងៗទៀត ក្រៅពីពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ និងផ្តល់ជូនសមាជិកក្រុមគ្រួសារដែលរស់នៅជាមួយ ដោយមិនប្រកាន់សញ្ជាតិអ្វីឡើយ នូវពេលវេលាចាំបាច់និងភាពងាយស្រួលទាំងឡាយ ដើម្បីផ្តល់លទ្ធភាពឱ្យជនទាំងនោះ រៀបចំការចេញដំណើរនិងចាកចេញក្នុងកាលដ៏គួរបំផុត បន្ទាប់ពីបញ្ចប់មុខងាររបស់សមាជិកទាំងនោះ ។ ជាពិសេសរដ្ឋម្ចាស់ផ្ទះ ក្នុងករណីចាំបាច់ផ្តល់ជូននូវមធ្យោបាយ ដឹកជញ្ជូនចាំបាច់ផ្សេងៗសំរាប់ពួកគេ ព្រមទាំងទ្រព្យសម្បត្តិរបស់គេលើកលែងតែទ្រព្យសម្បត្តិរកបាន ក្នុងរដ្ឋម្ចាស់ផ្ទះ ដែលការនាំចេញត្រូវហាមឃាត់ក្នុងវេរវេលានៃការចេញដំណើរ ។

## មាត្រា ៥១
## ការការពារទីស្ថាន និង សារឋានកុងស៊ុល
## និង ផលប្រយោជន៍នៃរដ្ឋដាក់កុងស៊ុល ក្នុងកាលៈទេសៈពិសេស

១. ក្នុងករណីនៃការផ្តាច់ទំនាក់ទំនងកុងស៊ុលរវាងរដ្ឋទាំងពីរ :

ក/. រដ្ឋម្ចាស់ផ្ទះ ទោះជាក្នុងករណីមានវិវាទដោយអាវុធក្តី នឹងត្រូវគោរពនិងការពារទីស្ថានកុងស៊ុល ព្រមទាំងទ្រព្យសម្បត្តិរបស់ប៉ុស្តិ៍កុងស៊ុលនិងសារឋានកុងស៊ុល ។

ខ/. រដ្ឋដាក់កុងស៊ុលអាចប្រគល់ការគ្រប់គ្រងទីស្ថានកុងស៊ុលរួម ព្រមទាំងទ្រព្យសម្បត្តិដែលស្ថិតនៅក្នុងនោះ និង សារឋានកុងស៊ុល ទៅរដ្ឋទីបីណាមួយ ដែលរដ្ឋម្ចាស់ផ្ទះអាចទទួលយល់ព្រម ។

គ/. រដ្ឋដាក់កុងស៊ុលអាចប្រគល់ការការពារនូវផលប្រយោជន៍របស់ខ្លួន និង របស់ពលរដ្ឋខ្លួន ទៅរដ្ឋទីបីណាមួយដែលរដ្ឋម្ចាស់ផ្ទះអាចទទួលយល់ព្រម ។

២. ក្នុងករណីមានការបិទប៉ុស្តិ៍កុងស៊ុលជាបណ្តោះអាសន្ន ឬ ជាស្ថាពរ បញ្ញាត្តិនៃវាក្យខណ្ឌ(ក) នៃកថាខណ្ឌទី១ នៃមាត្រានេះ នឹងត្រូវយកមកអនុវត្ត ។ លើសពីនោះ :

ក/. ប្រសិនបើរដ្ឋដាក់កុងស៊ុល ថ្វីបើពុំមានតំណាងដោយស្ថានបេសកកម្មការទូត នៅក្នុងរដ្ឋម្ចាស់ផ្ទះ មានប៉ុស្តិ៍កុងស៊ុលផ្សេងទៀតក្នុងដែនដីនៃរដ្ឋនោះ ប៉ុស្តិ៍កុងស៊ុលនេះអាចទទួលការគ្រប់គ្រងទីស្ថានរបស់ប៉ុស្តិ៍កុងស៊ុលដែលត្រូវបានបិទ ព្រមទាំងទ្រព្យសម្បត្តិដែលស្ថិតនៅក្នុងនោះ និង សារឋានកុងស៊ុល ដោយមានការយល់ព្រមនៃរដ្ឋម្ចាស់ផ្ទះ លើការបំពេញមុខងារកុងស៊ុល ក្នុងមណ្ឌលនៃប៉ុស្តិ៍កុងស៊ុលនោះ ដោយមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ ឬ

ខ/. ប្រសិនបើរដ្ឋដាក់កុងស៊ុលពុំមានស្ថានបេសកកម្មការទូត និងពុំមានប៉ុស្តិ៍កុងស៊ុលណាផ្សេងទៀតក្នុងរដ្ឋម្ចាស់ផ្ទះ បញ្ញាត្តិនៃវាក្យខណ្ឌ(ខ)និង(គ) នៃកថាខណ្ឌទី១នៃមាត្រានេះ នឹងត្រូវយកមកអនុវត្ត។

## មាត្រា ៥២

## ដំណឹងពីការប្រែប្រួលនៃច្បាប់ របស់រដ្ឋម្ចាស់ផ្ទះ ទាក់ទងទៅនឹងពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល

រដ្ឋម្ចាស់ផ្ទះត្រូវផ្តល់ដំណឹងទៅប៉ុស្តិ៍កុងស៊ុល ពីការប្រែប្រួលនៅក្នុងច្បាប់និងបទបញ្ញាត្តិរបស់ខ្លួន ទាក់ទងនឹងសិទ្ធិនិងផលប្រយោជន៍របស់រដ្ឋដាក់កុងស៊ុល និង ពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុលទាំងរូបវន្តបុគ្គលនិងនីតិបុគ្គល ។

## មាត្រា ៥៣

## ការផ្តល់សច្ចាប័ន ការចូលជាធរមាន និង ការលុបចោលនូវអនុសញ្ញានេះ

១. អនុសញ្ញានេះនឹងត្រូវដាក់សុំសច្ចាប័ន និងចូលជាធរមានក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃដែលភាគីចុះកិច្ចសន្យាទាំងពីរ បានផ្លាស់ប្តូរលិខិតសច្ចាប័នទៅវិញទៅមក ។

២. អនុសញ្ញានេះអាចធ្វើវិសោធនកម្មបាន ។ វិសោធនកម្មបែបនេះនឹងត្រូវបានចរចា

តាមផ្លូវទូត និង ត្រូវចូលជាធរមានក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃ ដែលភាគីចុះកិច្ចសន្យាបាន ផ្លាស់ប្តូរសំភារៈសច្ចាប័ន ស្តីពីការធ្វើវិសោធនកម្មនេះ ។

៣. អនុសញ្ញានេះត្រូវបានព្រមព្រៀងឡើងសំរាប់រយៈពេលមួយមិនកំណត់ និង ត្រូវស្ថិតនៅជាធរមានរហូតដុតរយៈពេល៦ខែ ចាប់ពីថ្ងៃដែលភាគីចុះកិច្ចសន្យាណាមួយ ប្រកាសជាលាយលក្ខអក្សរទៅភាគីម្ខាងទៀត អំពីបំណងបញ្ចប់នូវសុពលភាព នៃអនុសញ្ញារបស់ខ្លួននេះ ។

ធ្វើជាពីរច្បាប់នៅ . ភ្នំពេញ . . . ថ្ងៃទី 27 ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ជាភាសាខ្មែរ វៀតណាម និង អង់គ្លេស ។ អត្ថបទជាភាសាខ្មែរ និង វៀតណាម មានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយផ្ទុយគ្នា អត្ថបទជាភាសាអង់គ្លេស ត្រូវប្រើជាអត្ថបទគោល ។

| | |
|---|---|
| តំណាងអោយ | តំណាងអោយ |
| ព្រះរាជាណាចក្រកម្ពុជា | សាធារណរដ្ឋសង្គមនិយមវៀតណាម |
| អ៊ុង ហួត | ង្វៀង ម៉ាញ់ កឹម |

# CONSULAR CONVENTION
between
THE KINGDOM OF CAMBODIA
and
THE SOCIALIST REPUBLIC OF VIETNAM

*****

The Kingdom of Cambodia and the Socialist Republic of Vietnam, hereinafter referred to as the Contracting Parties,

Desiring to develop and further strengthen the friendly and traditional relations between the two countries,

Wishing to regulate and further develop the consular relations as well as create favourable conditions for the protection of legitimate rights and interests of citizens of one Contracting Party residing in the other's territory in conformity with international law and customs,

Have decided to conclude this Consular Convention and for this purpose have agreed upon the following:

## PART I

## DEFINITIONS

### Article 1

### Definitions

For the purpose of the present Convention, the terms mentioned hereinafter shall have the following meanings:

1. "Consular post" means any consulate-general, consulate, vice consulate and consular agency;

2. "Consular district" means the area assigned to a consular post for the exercise of consular functions;

3. "Head of a consular post" means the person appointed to act in that capacity;

4. "Consular officer" means any person, including the head of a consular post, who has been charged with the perfomance of consular functions in that capacity;

5. "Consular employee" means any person employed in the technical or administrative service of a consular post;

6. "Member of the service staff" means any person employed in the domestic service of a consular post;

7. "Members of the consular post" means consular officers, consular employees and members of the service staff;

8. "Members of the consular staff" means consular officers, other than the head of the consular post, consular employees and members of the service staff;

9. "Member of the private staff" means a person who is employed exclusively in the private service of a member of the consular post;

10." Consular premises" means the buildings or parts of buildings and the land ancillary thereto, irrespective of ownership, used exclusively for the purpose of the consular post;

11. "Consular archives" includes all the papers, documents, correspondence, books, films, tapes, technical means for information gathering and accumulation, registers of the consular post, together with the ciphers and codes, the card indexes and any articles of furniture used for their protection or safekeeping;

12. "Official correspondence" means all the correspondence relating to a consular post and its functions;

13. "Member of the family" of a consular officer or a consular employee means his wife or her husband and children under the age of 18, provided that they form a part of his or her household;

14. " Vessel " means any civil ship of navigation, sailing under the flag of the sending State in accordance with the latter's law, but does not include any warship;

15. "Aircraft" means any civil aircraft duly registered in the sending State which has the right of using the registration marks of that State, but does not include any military aircraft.

## PART II

## GENERAL PROVISIONS REGARDING CONSULAR RELATIONS

### Article 2

### Establishment of a consular post

1. A consular post may be established in the territory of the receiving State only with that State's consent.

2. The seat of the consular post, its classification and the consular district as well as the number of members of the consular staff shall be determined by the sending State and are subject to the approval of the receiving State.

3. Any subsequent change as regards the seat of the consular post, its classification, its consular district may be made by the sending State only with the consent of the receiving State.

4. The consent of the receiving State shall also be required if a consulate - general or a consulate desires to open a vice - consulate or a consular agency in a locality other than that in which it is itself established.

5. The prior express consent of the receiving State shall also be required for the opening of an office forming part of the existing consular post elsewhere than at the seat thereof.

### Article 3

### Appointment and admission of the head of a consular post

1. Prior to the appointment of the head of a consular post by the sending State, the consent of the receiving State concerning the proposed person shall be obtained through the diplomatic or other appropriate channels.

2. The receiving State which refuses its consent to the appointment of a person as the head of a consular post is not obliged to give the sending State reasons for such refusal.

3. The sending State shall transmit to the receiving State through the diplomatic or other appropriate channels the document in the form of Consular Commission or similar instrument for the appointment of the head of the consular post. This document shall certify his capacity and show his or her full name, his or her rank, the consular district and the seat of the consular post.

4. Upon receipt of the Consular Commission or similar instrument for the appointment of the head of the consular post, the receiving State shall issue to him or her an authorization termed an Exequatur, or other form of authorization.

5. Subject to the provision of the paragraph 6 of this Article and Article 4 of the present Convention, the head of a consular post may enter upon the exercise of his or her functions only after he or she has received an Exequatur or other authorization;

6. Pending the delivery of an Exequatur or other authorization, the receiving State, at the request of the sending state, may admit the head of a consular post to exercise his or her functions on a provisional basis. In that case the provisions of the present Convention shall apply.

7. As soon as the head of a consular post is admitted even provisionally to the exercise of his or her functions, the receiving State shall immediately notify the competent authorities of the consular district. It shall also ensure that the necessary measures are taken to enable the head of a consular post to carry out the duties of his or her office and to have the benefit of the provisions of this Convention.

## Article 4

### Temporary exercise of the functions of the head of a consular post

1. If the head of a consular post is unable to perform his/her functions or if the position of the head of the consular post is vacant, an acting head of post may act provisionally as head of the consular post.

2. The full name of the acting head of the consular post shall be notified to the Ministry of Foreign Affairs of the receiving State either by the diplomatic mission in the receiving State or, in default of that diplomatic mission in the receiving State, by the head of the consular post or, if he is unable to do so, by any other competent authorities of the sending State. As a general rule, this notification shall be given in advance. The receiving State may make the admission as acting head of the consular post of a person who is neither a diplomatic agent nor a consular officer of the sending State in the receiving State conditional on its consent.

3. The competent authorities of the receiving State shall grant assistance and protection to the acting head of the consular post. While he is in charge of the consular post, the provisions of the present Convention shall fully apply to the acting head of the post on the same basic as to the head of the consular post concerned. The receiving State shall not, however, be obliged to grant to an acting head of consular post any facility, privilege or immunity which the head of the consular post enjoys only subject to conditions not fulfilled by the acting head of the consular post.

4. When, in the circumstances referred to in paragraph 1 of this Article, a member of the diplomatic staff of the diplomatic mission of the sending State in the receiving State is appointed by the sending State as an acting head of the consular post, he or she shall, if the receiving State does not object thereto. continue to enjoy diplomatic privileges and immunities.

## Article 5

### Appointment of members of the consular staff

1. Subject to the provisions of Articles 2, 6 and 7 of the present Convention, the sending State may freely appoint the members of the consular staff.

2. The full name, category and class of each consular officer. other than the head of a consular post, shall be notified by the sending State to the receiving

State in sufficient time for the receiving State, if the latter so wishes, to exercise its rights under paragraph 3 of Article 7.

3. The competent authorities of the receiving State shall issue free of charge to all members of the consular post, members of their families and members of their private staff, documents confirming their identity and positions on the condition that they are not nationals or permanent residents of the receiving State.

## Article 6

### Nationality of consular officers

1. Consular officers should, in principle, have the nationality of the sending State.

2. Consular officer may be appointed from among persons having the nationality of or permanent residence in the receiving State only with the express consent of that State which may be withdrawn at any time.

3. The receiving State shall reserve itself rights under paragraph 2 of this Article concerning a national of a third State who are not also a national of the sending State.

## Article 7

### Persons declared "non grata" or unacceptable

1. The receiving State may at any time notify the sending State that a consular officer is *persona non grata* or that any other member of the consular staff is not acceptable. In that event, the sending State shall, as the case may be, either recall the person concerned or terminate his or her functions with the consular post.

2. If the sending State refuses or fails within a reasonable time to carry out its obligations under paragraph 1 of this Article, the receiving State may, as the case may be, either withdraw the Exequatur or other authorization from the person concerned or cease to consider him or her as a member of the consular staff.

3. A person appointed as a member of the consular post may be declared unacceptable before arriving in the territory of the receiving State or, if already in the receiving State, before entering on his or her duties with the consular post. In any such case, the sending State shall withdraw his or her appointment.

4. In the cases mentioned in paragraphs 1 and 3 of this Article, the receiving State is not obliged to give to the sending State reasons for its decisions.

## Article 8

## Notification to the receiving State of appointments, arrivals and departures

1. The Ministry for Foreign Affairs of the receiving State or the authority designated by that Ministry shall be notified of:

a) the appointment of members of a consular post, their arrival after appointment to the consular post, their final departure or the termination of their functions and any other changes affecting their status that may occur in the course of their service with the consular post;

b) the arrival and final departure of a person belonging to the family of a member of a consular post and, where appropriate, the fact that a person becomes or ceases to be such a member of the family;

c) the arrival and final departure of a member of the private staff and, where appropriate, the termination of his service as such; and

d) the engagement and discharge of persons residing in the receiving State as members of a consular post or as members of the private staff entitled to privileges and immunities.

2. When possible, prior notification of arrival and final departure shall be given.

## Article 9

## Acquisition of consular premises and residences

1. The sending State shall be entitled, on its own or through any natural person or body corporate authorized by it, in accordance with the laws and

regulations of the receiving State and with the permission of that State, to acquire ownership, lease, rent, or any other form of tenure:

a) consular premises, a residence for the head of the consular post, and a residence for each consular officer and each consular employee who is not a national of or a permanent resident in the receiving State;

b) land and any such premises and residences constructed thereon.

2. Under the conditions referred to in paragraph 1, the sending State may also improve such premises, residences or land.

3. The receiving State shall render all appropriate assistance and support to the sending State in carrying out the rights specified in paragraphs 1 and 2 of this Article.

4. The sending State shall comply with the laws and regulations of the receiving State relating to siting and design of buildings, and the laws and regulations relating to town planning and zoning.

5. The rentals and other charges for premises and residences referred to in paragraphs 1 and 2 of this Article shall be at a similar level to the rentals and other charges generally applying in respect of similar premises which are not used as diplomatic or consular premises.

## Article 10

### Honorary consular officers

Both Contracting Parties consent to the appointment of an honorary consular officer. They shall consult each other about the establishment of arrangements, based on the provisions of this Convention.

## PART III

## FACILITIES, PRIVILEGES AND IMMUNITIES

## Article 11

### Protection of and facilities for consular posts and members of consular posts

1. The receiving State shall accord full facilities for the performance of the functions of the consular post.

2. The receiving State shall treat consular officers with due respect and shall take all appropriate measures to prevent any attack on their person, freedom or dignity or on other members of the consular post and members of the family of any aforementioned person.

## Article 12

### Use of national flag and coat-of-arms

1. The sending State shall have the right to the use of its national flag and coat-of-arms in the receiving States in conformity with the provisions of this Article.

2. The national flag of the sending State may be flown and its coat-of-arms displayed together with an appropriate inscription in the languages of the sending and receiving States on the building occupied by the consular post and at the entrance door thereof, in the residence of the head of the consular post as well as on the means of transport used by him or her for official purposes.

3. In exercising the right provided by this Article. the sending State shall observe the laws, regulations and usages of the receiving State.

## Article 13

### Inviolability of the consular premises

1. The consular premises shall be inviolable to the extent provided in this Article.

2. The authorities of the receiving State shall not enter that part of the consular premises which is used exclusively for the purpose of the work of the consular post, except with the consent of the head of the consular post of the sending State, or of his/her designee or of the head of the diplomatic mission of the sending State. The consent of the head of the consular post may, however, be assumed in case of fire or other disaster requiring prompt protective action.

3. Subject to the provisions of paragraph 2 of this Article, the receiving State is under a special duty to take all appropriate measures to protect the consular premises against any intrusion or damage and to prevent any disturbance of the peace of the consular post or impairment of its dignity.

4. The consular premises, their furnishings, the property of the consular post and its means of transport shall be immune from any form of the requisition for purposes of national defence or public utility. If expropriation is necessary for such purposes, all possible steps shall be taken to avoid impeding the performance of consular functions, and prompt, adequate and effective compensation shall be paid to the sending State.

## Article 14

### Exemption from taxation of consular premises

1. The consular premises and the residence of the career head of the consular post of which the sending State or any person acting on its behalf is the owner or the lessee, shall be exempt from all taxes and dues, either national, regional or municipal, other than such as represent payment for the specific services rendered.

2. The exemption from taxation referred to in paragraph 1 of this Article shall not apply to such taxes and dues if under the laws and regulations of the receiving State, they are payable by the person who contracted with the sending State or with the person acting on behalf of such State.

## Article 15

### Inviolability of consular archives and documents

The consular archives and documents shall be inviolable at all times and wherever they may be.

## Article 16

### Freedom of movement

Subject to its laws and regulations concerning zones entry into which is prohibited or restricted for reasons of national security or public order and safety, the receiving State shall ensure freedom of movement and travel in its territory to

all members of the consular post. In any circumstance, however, the receiving State shall provide facilities for consular officers to perform their duties.

## Article 17

### Freedom of communication

1. The receiving State shall permit and protect freedom of communication on the part of the consular post for all official purposes.

In communicating with the Government, the diplomatic missions and other consular posts of the sending State, wherever situated, the consular post may employ all appropriate means, including diplomatic or consular couriers, diplomatic or consular bags, messages in code or cipher. However, the consular post may install and use a wireless-transmitter only with the consent of the receiving State.

2. The official correspondence of the consular post is inviolable.

3. The consular bag shall be neither opened nor detained. Nevertheless, if the competent authorities of the receiving State have serious reason to believe that the consular bag contains something other than the correspondence, documents or articles referred to in paragraph 4 of this Article, they may request that the consular bag be opened in their presence by an authorized representative of the sending State. If this request is refused by the authorised representative of the Sending State, the consular bag shall be returned to its place of origin.

4. The packages constituting the consular bag shall bear visible external marks of their character and may contain only official correspondence and documents or articles intended exclusively for official use.

5. The consular courier shall be provided with an official document indicating his or her status and the number of packages constituting the consular bag. Except with the consent of the receiving State, he or she may be neither a national of the receiving State nor a permanent resident in the receiving State. In the performance of his or her functions, the consular courier shall be protected by the receiving State. He or she shall enjoy personal inviolability and shall not be liable to any form of arrest, detention or any other form of limitation of his or her personal freedom.

6. The sending State, its diplomatic missions and its consular posts may designate consular couriers ad hoc. In such cases the provisions of paragraph 5 of

this Article shall also apply except that the immunities therein mentioned shall cease to apply when such a courier has delivered to the consignee the consular bag in his or her charge.

7. A consular bag may be entrusted to the captain of a vessel or of a commercial aircraft which is due to arrive in an authorized port of entry. He or she shall be provided with an official document indicating the number of packages constituting the consular bag, but he or she shall not be considered to be a consular courier. By arrangement with the competent local authorities, the consular post shall send one of its members to take possession of the bag directly and freely from the captain of the vessel or of the aircraft or to deliver the bag in the same way.

## Article 18

### Personal inviolability of consular officers and notification of proceedings against members of the consular staff

1. Consular officers shall not be liable to arrest or detention, except in the case of a grave crime and pursuant to a decision by the competent judicial authority.

2. Except in the case specified in paragraph 1 of this Article, consular officers shall not be committed to prison or liable to any other form of restriction on their personal freedom, save in execution of a judicial decision of final effect.

3. If criminal proceedings are instituted against a consular officer, he or she must appear before the competent authorities. However, the proceedings shall be conducted with the respect due to him or her by reason of his or her official position and, except in the case specified in paragraph 1 of this Article, in a manner which will hamper the exercise of consular functions as little as possible. When in the circumstances mentioned in paragraph 1 of this Article, it has become necessary to detain a consular officer, the proceedings against him or her shall be instituted with the minimum of delay.

4. In the case of the arrest or detention of a member of the consular staff, or of criminal proceedings being instituted against that person, the receiving State shall promptly notify the head of the consular post. Should the latter be himself the object of any such measure, the receiving State shall notify the sending State through the diplomatic channel.

## Article 19

Immunity from jurisdiction

1. Consular officers and consular employees shall not be amenable to the jurisdiction of the judicial or administrative authorities of the receiving State in respect to acts performed in the exercise of consular functions.

2. The provisions of paragraph 1 of this Article shall not, however, apply to a civil action either:

a) arising out of a contract concluded by a consular officer or a consular employee in which he did not contract expressly or impliedly as an agent on behalf of the sending State; or

b) by a third party for damage arising from an accident in the receiving State caused by a vehicle, vessel or aircraft.

Article 20

Liability to give evidence

1. Members of a consular post may be called upon to attend as witnesses in the course of judicial or administrative proceedings. A consular employee or a member of the service staff shall not, except in the cases mentioned in paragraph 3 of this Article, decline to give evidence. If a consular officer should decline to do so, no coercive measure or penalty may be applied to him or her.

2. The authority requiring the evidence of a consular officer shall avoid interference with the performance of his or her functions. It may, when possible, take such evidence in his or her residence or at the consular post or accept a statement from him or her in writing.

